ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សេចក្តីណែនាំលម្អិត

# ស្តីពី

# ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត

២០១២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៦៥០៨ អយក.ឧមន

# លិខិតឧទ្ទេសនាម

យោង: - អនុក្រឹត្យលេខ ១៥១ អនក្រ.បក ចុះថ្ងៃទី ០៦ខែធ្នូ ឆ្នាំ២០១០ ស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត
- តាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

ឯកឧត្តម លោកជំទាវ លោកបណ្ឌិត លោកសាស្ត្រាចារ្យដែលមានរាយនាមខាងក្រោមនេះត្រូវបានចាត់តាំងជាក្រុមការងាររៀបចំសេចក្ដីណែនាំលម្អិតស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត និងផែនការអភិវឌ្ឍន៍ការស្រាវជ្រាវក្នុងវិស័យអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា។

| | | | |
|---|---|---|---|
| ១. លោកជំទាវបណ្ឌិត | **ភឿង សកុណា** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ប្រធាន |
| ២. ឯកឧត្តម | **ហាក់ សឹងលី** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៣. ឯកឧត្តមបណ្ឌិត | **ម៉ក់ ផាឡន** | អគ្គនាយកឧត្តមសិក្សា | អនុប្រធាន |
| ៤. លោកបណ្ឌិត | **វ៉ាន់ ច័ន្ទផេន** | អគ្គនាយករងឧត្តមសិក្សា | សមាជិក |
| ៥. លោក | **ម៉ក់ ខយ** | អគ្គនាយករងឧត្តមសិក្សា | សមាជិក |
| ៦. លោកបណ្ឌិត | **ច័ន្ទ រ័ត្ន** | ប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | លេខាធិការ |
| ៧. លោកបណ្ឌិត | **ជ័យ សារិន** | អនុប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ៨. លោកបណ្ឌិត | **ឱន ច័ន្ទរិទ្ធ** | សាស្ត្រាចារ្យសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៩. លោកបណ្ឌិត | **កង សុវណ្ណារ៉ា** | សាស្ត្រាចារ្យសាកលវិទ្យាល័យជាតិគ្រប់គ្រង | សមាជិក |
| ១០. តំណាងរាជបណ្ឌិតសភាកម្ពុជាចំនួន ១ រូប | | | សមាជិក |
| ១១. តំណាងសមាគមគ្រឹះស្ថានឧត្តមសិក្សាចំនួន ២រូប | | | សមាជិក |

ឯកឧត្តម លោកជំទាវ លោកបណ្ឌិត លោកសាស្ត្រាចារ្យ ដែលមានរាយនាមខាងលើត្រូវចូលរួមប្រជុំនិងទទួលភារកិច្ចតាមការអញ្ជើញនិងចាត់តាំងរបស់ប្រធាន។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

អ៊ឹម_សិទ្ធី

កន្លែងទទួល:
- អង្គភាពពាក់ព័ន្ធ"ដើម្បីជូនជ្រាប"
- សាមីជន"ដើម្បីអនុវត្តន៍"
- ឯកសារ-កាលប្បវត្តិ នា.សវ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងអប់រំ យុវជន និងកីឡា

# សេចក្តីណែនាំលម្អិត
# ស្តីពី
# ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត

## ជំពូកទី១
## លក្ខណៈសម្គាល់នៃការបណ្តុះបណ្តាលថ្នាក់បណ្ឌិត

### ១.១ បណ្ឌិតស្រាវជ្រាវ

ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតស្រាវជ្រាវត្រូវសង្កត់ធ្ងន់ទៅលើការកសាងសមត្ថភាពស្រាវជ្រាវរបស់បេក្ខជនទាំងចំណេះដឹងអំពីទ្រឹស្តី វិធីសាស្ត្រស្រាវជ្រាវ អំណាននិរិះគន់និងវិភាគ អភិវឌ្ឍន៍សំណើនិងគម្រោងស្រាវជ្រាវ ហើយនិងបំណិនក្នុងការនិពន្ធនិងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវតាមរយៈការចុះអត្ថបទទស្សនាវដ្តីវិទ្យាសាស្ត្រនិងរៀបចំនិក្ខេបបទត្រឹមត្រូវទៅតាមទម្រង់ស្តង់ដាណាមួយដែលបានកំណត់។ បេក្ខជនត្រូវមានភាពប៉ិនប្រសប់ក្នុងការឡើងធ្វើបទបង្ហាញការពារបេកគំហើញនិងចេះទទួលយកនូវការរិះគន់កែលម្អលើលទ្ធផលស្រាវជ្រាវរបស់ខ្លួននៅតាមជំនួបប្រជុំនានានៃសហគមន៍អ្នកវិទ្យាសាស្ត្រ។

បណ្ឌិតស្រាវជ្រាវជាប្រភេទបណ្ឌិតដែលបណ្តុះបណ្តាលដោយភាគច្រើនទៅតាមមុខជំនាញសិក្សានានាដែលមាននៅក្នុងកម្មវិធីឧត្តមសិក្សា។ បណ្ឌិតប្រភេទនេះ ជាតម្រូវការចាំបាច់ជាងគេសម្រាប់អ្នកស្រាវជ្រាវវិទ្យាសាស្ត្រនិងសាស្ត្រាចារ្យសាកលវិទ្យាល័យ។

### ១.២ បណ្ឌិតវិជ្ជាជីវៈ

ការបណ្តុះបណ្តាលបណ្ឌិតវិជ្ជាជីវៈ ត្រូវសំដៅចំពោះតែបុគ្គលណាដែលបាន ឬ/និងកំពុងបំពេញការងារប្រចាំថ្ងៃរបស់ខ្លួនពាក់ព័ន្ធនឹងមុខជំនាញជ្រើសរើស ក្នុងរយៈពេលមួយដ៏សមស្រប។ កម្មវិធីបណ្តុះបណ្តាលនេះត្រូវយកចិត្តទុកដាក់ជាសំខាន់ទៅលើការពង្រឹងចំណេះដឹងវិជ្ជាជីវៈមូលដ្ឋាននិងកម្រិតជំនាញពាក់ព័ន្ធដោយគួបផ្សំជាមួយបទពិសោធន៍សមល្មម ដែលបេក្ខជនអាចប្រតិបត្តិវិធីសាស្ត្រវិទ្យាសាស្ត្រក្នុងការស្រាវជ្រាវនិងរៀបចំចងក្រងជាស្នាដៃថ្មីមួយដែលអាច ទទួលស្គាល់បានហើយនិងអាចរួមចំណែកជំរុញសមត្ថភាពវិជ្ជាជីវៈផ្ទាល់ខ្លួនរបស់បេក្ខជន ក៏ដូចជាភាពជឿនលឿនរបស់ជំនាញវិជ្ជាជីវៈនោះឱ្យកាន់តែប្រសើរឡើង។

បណ្ឌិតវិជ្ជាជីវៈជាប្រភេទបណ្ឌិតដែលបណ្តុះបណ្តាលសម្រាប់មុខជំនាញវិជ្ជាជីវៈមួយចំនួនដូចជា វេជ្ជសាស្ត្រ ទន្តវេទនសាស្ត្រ ឱសថសាស្ត្រ ធុរកិច្ច នីតិសាស្ត្រ វិស្វកម្ម អប់រំ រដ្ឋបាលសាធារណៈ វិចិត្រសិល្បៈ ... ដើម្បីលើកកម្ពស់សមត្ថភាព វិជ្ជាជីវៈបច្ចុប្បន្នរបស់បេក្ខជនឱ្យកាន់តែស៊ីជម្រៅ និង បានផ្សព្វផ្សាយទូលាយ។

មុខជំនាញមួយចំនួន អាចមានការបណ្តុះបណ្តាលថ្នាក់បណ្ឌិតទាំងពីរប្រភេទ អាស្រ័យទៅតាមគោលបំណងនៃកម្មវិធីបណ្តុះបណ្តាល។

## ជំពូកទី២
## ការជ្រើសរើសនិស្សិតឱ្យចូលរៀន

### ២.១ រយៈពេលនិងរូបភាពជ្រើសរើស

គ្រឹះស្ថានបណ្តុះបណ្តាលនីមួយៗអាចជ្រើសរើសនិស្សិតឱ្យចូលរៀនបានតែមួយដងក្នុងមួយឆ្នាំសិក្សា។ ការផ្សព្វផ្សាយព័ត៌មានជ្រើសរើសត្រូវធ្វើឡើងយ៉ាងតិចបី(៣)ខែមុនកាលបរិច្ឆេទប្រឡងជ្រើសរើស និងឱ្យបានទូលំទូលាយជាសាធារណៈ។

ការប្រឡងជ្រើសរើសត្រូវធ្វើឡើងតាមរូបភាព ពិនិត្យសំណុំឯកសារ និងការសម្ភាសន៍លើសំណើស្រាវជ្រាវបឋមដោយផ្ទាល់។

### ២.២ លក្ខខណ្ឌសម្រាប់ការជ្រើសរើស

ការចូលសិក្សាថ្នាក់បណ្ឌិត និស្សិតត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- បានឆ្លងកាត់គ្រប់កម្រិតបណ្តុះបណ្តាលក្នុងប្រព័ន្ធឧត្តមសិក្សា (មានសញ្ញាបត្របរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់)
- ទទួលបានពិន្ទុមធ្យមភាគសរុប(GPA)ចាប់ពី ៣.០០ ឡើងទៅ ឬនិស្សិតសរសេរនិក្ខេបបទក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
- មានសំណើគម្រោងស្រាវជ្រាវបឋមច្បាស់លាស់
- មានសមត្ថភាពភាសាអន្តរជាតិណាមួយទៅតាមការកំណត់របស់កម្មវិធី និងមានមូលដ្ឋានគ្រឹះព័ត៌មានវិទ្យាសម្រាប់ប្រើប្រាស់ក្នុងការស្រាវជ្រាវ។

ចំនួននិស្សិតចូលសិក្សា ត្រូវកំណត់លើសមត្ថភាពនិងលទ្ធភាពធនធានរបស់គ្រឹះស្ថានបណ្តុះបណ្តាលក្នុងការជួយគាំទ្រនិស្សិតថ្នាក់បណ្ឌិតទាំងនោះ ហើយនិងគុណវុឌ្ឍិរបស់បេក្ខជនដែលត្រូវជ្រើសរើស។

### ២.៣ ការផ្សព្វផ្សាយព័ត៌មានជ្រើសរើស

គ្រឹះស្ថានបណ្តុះបណ្តាលនីមួយៗ ត្រូវមានផែនការច្បាស់លាស់សម្រាប់ការផ្សព្វផ្សាយព័ត៌មានជ្រើសរើស ហើយព័ត៌មានទាំងនោះមាន៖

- ទីតាំង និងមូលដ្ឋានសម្ភារសម្រាប់ទ្រទ្រង់ដំណើរការបណ្តុះបណ្តាល
- អាស័យដ្ឋានទំនាក់ទំនង
- កម្មវិធីសិក្សា ជំនាញដែលជ្រើសរើស និងចំនួននិស្សិតដែលគ្រោងជ្រើសរើស
- លក្ខខណ្ឌសម្រាប់ការជ្រើសរើស
- ចំនួនសាស្ត្រាចារ្យបង្រៀន សាស្ត្រាចារ្យណែនាំ និងរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់បណ្ឌិត
- លិខិតបទដ្ឋានដែលអនុញ្ញាតឱ្យបើកដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- ថ្លៃសិក្សា និងរចនាសម្ព័ន្ធថ្លៃសិក្សា
- រយៈពេលសិក្សា អប្បបរមា និង អតិបរមា។

### ២.៤ សំណុំលិខិតដាក់ពាក្យជ្រើសរើស

សំណុំលិខិតដាក់ពាក្យជ្រើសរើសមាន៖

- ប្រវត្តិរូបសង្ខេបរបស់បេក្ខជន មួយ(១)ច្បាប់
- ពាក្យចុះឈ្មោះចូលរៀនរបស់បេក្ខជន មួយ(១)ច្បាប់
- លិខិតបិទជិតរបស់អ្នកផ្តល់យោបល់បី(៣)រូប អ្នកគ្រប់គ្រង១រូប និង សាស្ត្រាចារ្យធ្លាប់ណែនាំ២រូប

- ច្បាប់ចតចម្លងបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ដោយមានការបញ្ជាក់ពីសាលារាជធានី ឬ សាលាខេត្ត
- ព្រឹត្តិបត្រពិន្ទុដែលបានសិក្សានៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងបរិញ្ញាបត្រ មួយ(១)ច្បាប់
- វិញ្ញាបនបត្របញ្ជាក់កម្រិតភាសាអង់គ្លេស ឬ ភាសាអន្តរជាតិណាមួយដែលអាចទទួលស្គាល់បាន
- វិញ្ញាបនបត្របញ្ជាក់កម្រិតមូលដ្ឋានគ្រឹះព័ត៌មានវិទ្យាសម្រាប់ការស្រាវជ្រាវដែលអាចទទួលស្គាល់បាន
- សំណើគម្រោងស្រាវជ្រាវបឋម។

## ២.៥ ការរៀបចំយន្តការប្រឡងជ្រើសរើស

គ្រឹះស្ថានបណ្តុះបណ្តាលទាំងអស់ ត្រូវសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតគណៈកម្មការប្រឡងជ្រើសរើស ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| - រដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា | ១រូប | ប្រធាន |
| - អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា | ១រូប | អនុប្រធាន |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា | | អនុប្រធាន |
| - អគ្គនាយករងនៃអគ្គនាយកដ្ឋានឧត្តមសិក្សា | ១រូប | សមាជិក |
| - ប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | | សមាជិក |
| - អនុប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | | សមាជិក |
| - សាកលវិទ្យាធិការឬនាយកគ្រឹះស្ថានបណ្តុះបណ្តាល | | សមាជិក |
| - សាកលវិទ្យាធិការរងឬនាយករង និងមន្ត្រីជំនាញនៃគ្រឹះស្ថានបណ្តុះបណ្តាល | | សមាជិក |
| - ប្រធានការិយាល័យស្រាវជ្រាវនៃនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | | សមាជិក |

គណៈកម្មការប្រឡងជ្រើសរើសនេះមានសិទ្ធិបង្កើតអនុគណៈកម្មការកណ្តាល អនុគណៈកម្មការមុខជំនាញ និង អនុគណៈកម្មការផ្សេងៗទៀត តាមតម្រូវការចាំបាច់ ដើម្បីឱ្យដំណើរការប្រឡងជ្រើសរើសប្រព្រឹត្តទៅដោយជោគជ័យ។

## ២.៦ ការទទួលនិងពិនិត្យសំណុំលិខិតជ្រើសរើស

អនុគណៈកម្មការកណ្តាល ជាសេនាធិការឱ្យគណៈកម្មការប្រឡងជ្រើសរើស និងមានភារកិច្ចរៀបចំបញ្ជីឈ្មោះ ផ្ទៀងផ្ទាត់សំណុំលិខិត និងធ្វើសម្រង់ឈ្មោះបេក្ខជនដែលគ្រប់លក្ខខណ្ឌតាមការជ្រើសរើស ហើយនិងរៀបចំសំណុំឯកសារទៅតាមជំនាញសម្រាប់ដាក់ជូន អនុគណៈកម្មការមុខជំនាញដើម្បីជ្រើសរើស។ បន្ទាប់មករៀបចំកាលបរិច្ឆេទសម្រាប់អនុគណៈកម្មការមុខជំនាញនីមួយៗ មកប្រជុំជ្រើសរើស។

## ២.៧ ការរៀបចំអនុគណៈកម្មការមុខជំនាញ

គណៈកម្មការប្រឡងជ្រើសរើសត្រូវរៀបចំអនុគណៈកម្មការទៅតាមមុខជំនាញ ដោយផ្អែកលើសំណុំលិខិតដាក់ពាក្យតាមមុខជំនាញនិងទិសដៅសំណើស្រាវជ្រាវរបស់បេក្ខជន។ អនុគណៈកម្មការមុខជំនាញនីមួយៗ ត្រូវមានសមាសភាពយ៉ាងតិចបី(៣)រូប ដែលមានសញ្ញាបត្របណ្ឌិត ក្នុងនោះមានប្រធានមួយរូបដឹកនាំ។

អនុគណៈកម្មការតាមមុខជំនាញត្រូវមានភារកិច្ចចូលរួមជ្រើសរើសបេក្ខជននិស្សិតនៅក្នុងមុខជំនាញរបស់ខ្លួន និងទទួលខុសត្រូវនៅចំពោះមុខគណៈកម្មការប្រឡងជ្រើសរើស។

## ២.៨ ការពិនិត្យ និងប្រឡងជ្រើសរើស

ជាទូទៅការជ្រើសរើសនិស្សិតថ្នាក់បណ្ឌិតត្រូវធ្វើឡើងជាពីរជំហាន។ ជំហានទីមួយត្រូវធ្វើឡើង ដោយការពិនិត្យសំណុំលិខិតបេក្ខជន និងជំហានទីពីរ គឺការវាយតម្លៃលើការឡើងបង្ហាញសំណើស្រាវជ្រាវបឋមរបស់បេក្ខជន។

១. អនុគណៈកម្មការកណ្តាល ត្រូវរៀបចំផែនការនិងកាលបរិច្ឆេទនៃការពិនិត្យនិងប្រឡងជ្រើសរើស ហើយជូនដំណឹងដល់គ្រប់សមាជិកអនុគណៈកម្មការមុខជំនាញដើម្បីជួបជុំគ្នា។ គណៈកម្មការប្រឡងជ្រើសរើស ត្រូវរៀបចំជូនដំណឹងដល់បេក្ខ ជនយ៉ាងតិច១៥ថ្ងៃមុនកាលបរិច្ឆេទពិនិត្យនិងប្រឡងជ្រើសរើស អំពីពេលវេលា និងទីកន្លែងប្រឡង។

២. អនុគណៈកម្មការកណ្តាល ត្រូវរៀបចំអត្រាពិន្ទុសម្រាប់ឱ្យអនុគណៈកម្មការជំនាញនីមួយៗ ផ្តល់កំណែទៅលើ៖

ក. សំណុំឯកសារបេក្ខជន ត្រូវមានប្រវត្តិរស់នៅ ការសិក្សានិងការងារ វិញ្ញាបនបត្របញ្ជាក់អំពីសមត្ថភាពភាសាអន្តរជាតិ និង មូលដ្ឋានគ្រឹះប្រើប្រាស់ព័ត៌មានវិទ្យាសម្រាប់ការស្រាវជ្រាវដែលអាចទទួលស្គាល់បាន។

ខ. សម្រង់ស្ថិតិស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រ មានដូចជា របាយការណ៍ស្រាវជ្រាវ អត្ថបទស្រាវជ្រាវដែលបានចុះផ្សាយសារណាបរិញ្ញាបត្រ និង របាយការណ៍ ឬនិក្ខេបបទបរិញ្ញាបត្រជាន់ខ្ពស់ ហើយនិងស្នាដៃបោះពុម្ពផ្សាយដទៃទៀត ព្រមទាំងកម្រិតគុណភាពនៃស្នាដៃទាំងនោះ។

គ. សំណើគម្រោងស្រាវជ្រាវបឋមរបស់បេក្ខជន គឺជាសំណេរដែលត្រូវបង្ហាញអំពី បំណងប្រាថ្នាទៅលើប្រធានបទអ្វីមួយ អត្ថប្រយោជន៍របស់វា និងអំពីឆន្ទៈនិងកម្រិតសមត្ថភាពគ្រោងដោះស្រាយរបស់បេក្ខជន។

អនុគណៈកម្មការកណ្តាល ត្រូវរៀបចំបញ្ជីឈ្មោះបេក្ខជន សេចក្តីណែនាំផ្សេងៗក្នុងការជ្រើសរើសសំណុំលិខិតបេក្ខជន និងសាលាកបត្រវាយតម្លៃសំណុំឯកសាររបស់បេក្ខជន បញ្ជូនទៅឲ្យអនុគណៈកម្មការមុខជំនាញនីមួយៗរៀបចំការផ្តល់ពិន្ទុ។

៣. អនុគណៈកម្មការមុខជំនាញនីមួយៗ មានភារកិច្ចពិនិត្យផ្តល់ពិន្ទុតាមអត្រាណែនាំទៅលើសំណុំឯកសាររបស់បេក្ខជនបន្ទាប់មកបូកពិន្ទុសរុបម្នាក់ៗ ដើម្បីរៀបចំជាបញ្ជីតាមលំដាប់ចំណាត់ថ្នាក់ រួចហើយស្នើជាបញ្ជីជ្រើសរើសជំហានទីមួយប្រគល់ជូនគណៈកម្មការប្រឡងជ្រើសរើសពិនិត្យសម្រេច។ បេក្ខជនដែលមានឈ្មោះជាប់ក្នុងបញ្ជីជ្រើសរើសជំហានទីមួយត្រូវមកបន្តធ្វើការប្រឡងជំហានទីពីរតាមរយៈការឡើងបង្ហាញសំណើគម្រោងស្រាវជ្រាវបឋមអំពីប្រធាន បទរបស់ ខ្លួននៅចំពោះមុខអនុគណៈកម្មការមុខជំនាញទៅតាមលំដាប់លំដោយដូចខាងក្រោម៖

ក. អនុគណៈកម្មការមុខជំនាញ ស្តាប់បេក្ខជនឡើងបង្ហាញម្នាក់ម្តងអំពីប្រធានបទស្រាវជ្រាវ និងគម្រោងការណ៍ប្រតិបត្តិ ដើម្បីបង្ហាញអំពីកម្រិតសមត្ថភាពនិងលទ្ធភាពស្រាវជ្រាវ និង ដំណោះស្រាយរបស់ខ្លួន។

ខ. បន្ទាប់មកសមាជិកអនុគណៈកម្មការមុខជំនាញចោទសំណួរដោយផ្ទាល់ចំពោះបេក្ខជន ហើយស្តាប់ចម្លើយរបស់គេដើម្បីវាស់ស្ទង់សមត្ថភាពបេក្ខជនរួចហើយវាយតម្លៃនិងផ្តល់ពិន្ទុនៅលើសាលាកប័ត្រដែលគណៈកម្មការកណ្តាល បានផ្តល់ជូន។

គ. នៅចុងក្រោយបង្អស់អនុគណៈកម្មការជំនាញនីមួយៗ បូកសរុបលទ្ធផលពិន្ទុវាយតម្លៃរបស់សមាជិកទាំងអស់ទៅលើបេក្ខជនម្នាក់ៗ រួចហើយរៀបចំជាបញ្ជីចំណាត់ថ្នាក់បេក្ខជនតាមលំដាប់ពិន្ទុពីខ្ពស់មកទាប បន្ទាប់មកបញ្ជូនលទ្ធផលទាំងនេះ ទៅឲ្យគណៈកម្មការប្រឡងជ្រើសរើសពិនិត្យសម្រេច។

ដោយឡែកសម្រាប់បេក្ខបណ្ឌិតវិជ្ជាជីវៈ ជំហានទីមួយគឺ (ក) ការពិនិត្យនិងវាយតម្លៃទៅលើសំណុំឯកសារបេក្ខជន (ខ) សម្រង់ស្ថិតិបទពិសោធន៍វិជ្ជាជីវៈនិងការធ្លាប់បោះពុម្ពផ្សាយ និង (គ) សំណើគម្រោងស្រាវជ្រាវរបស់បេក្ខជន និងជំហានទីពីរ គឺការឡើងបង្ហាញសំណើគម្រោងការណ៍ស្រាវជ្រាវបែបសកម្មភាពរបស់បេក្ខជន។

## ២.៩ ការប្រកាសលទ្ធផលជ្រើសរើស

អនុគណៈកម្មការកណ្តាលមានភារកិច្ចត្រួតពិនិត្យឡើងវិញជាចុងក្រោយនូវរាល់សំណុំឯកសារលទ្ធផលដែលបញ្ជូនមកធ្វើរបាយការណ៍បូកសរុប រួចហើយបញ្ជូនលទ្ធផលចុងក្រោយទៅឱ្យគណៈកម្មការប្រឡងជ្រើសរើស។ ផ្អែកតាមគោលការណ៍ពិនិត្យជ្រើសរើសដោយសមធម៌និងយុត្តិធម៌ទៅលើគុណវុឌ្ឍិបេក្ខជនដែលបានកំណត់ទុក គណៈកម្មការប្រឡង

ជ្រើសរើសយល់ព្រមនិងសម្រេចទៅតាមវិស័យនិងមុខជំនាញបណ្តុះបណ្តាលមួយម្តងៗ លើមូលដ្ឋានលទ្ធផលប្រឡងជ្រើសរើសជំហានទាំងពីរ។ ប្រធានគណៈកម្មការប្រឡងជ្រើសរើសចុះហត្ថលេខាទទួលស្គាល់ លើបញ្ជីឈ្មោះបេក្ខជនដែលបានជ្រើសរើសឱ្យចូលសិក្សា។ បញ្ជីឈ្មោះបេក្ខជនដែលបានជ្រើសរើសទាំងនេះត្រូវបិទ ផ្សាយនិងផ្សព្វផ្សាយជាសាធារណៈឱ្យដល់បេក្ខជនចូលរួមគ្រប់ៗគ្នា។

## ២.១០ ការបូកសរុបនិងរាយការណ៍ការងារប្រឡងជ្រើសរើស

អនុគណៈកម្មការកណ្តាលត្រូវរៀបចំធ្វើរបាយការណ៍អំពីដំណើរការប្រឡងជ្រើសរើសចាប់តាំងពីការត្រៀមរៀបចំរហូតដល់ការប្រកាសលទ្ធផល ព្រមទាំងហេតុការណ៍ផ្សេងៗ ដែលកើតមានជូនប្រធានគណៈកម្មការប្រឡងជ្រើសរើសឯកភាពនិងចុះហត្ថលេខា។

របាយការណ៍នេះនិងបញ្ជីឈ្មោះបេក្ខជនដែលបានជ្រើសរើស ត្រូវបញ្ជូនឱ្យទាន់ពេលវេលាទៅក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងអាណាព្យាបាល។

## ២.១១ ការរក្សាទុកសំណុំឯកសារនិស្សិតថ្នាក់បណ្ឌិត

គ្រឹះស្ថានបណ្តុះបណ្តាលថ្នាក់បណ្ឌិតត្រូវរៀបចំបញ្ជីឈ្មោះនិស្សិតថ្នាក់បណ្ឌិតដោយផ្អែកតាមលទ្ធផលនៃការជ្រើសរើសរបស់គណៈកម្មការ និងរៀបចំសំណុំឯកសាររបស់និស្សិតម្នាក់ៗ រួមមានការត្រួត ពិនិត្យឡើងវិញ ការឱ្យបំពេញបន្ថែម ការរក្សាទុក និងការសន្សំបន្ថែមជាទៀងទាត់តាមការកំណត់របស់គ្រឹះស្ថានបណ្តុះបណ្តាល។

## ២.១២ ការរៀបចំបវេសនកាល

ការរៀបចំបវេសនកាលកម្មវិធីថ្នាក់បណ្ឌិតសម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលនីមួយៗ ត្រូវធ្វើឡើងជាទៀងទាត់ក្នុងមួយឆ្នាំម្តង។ ផ្នែកគ្រប់គ្រងកម្មវិធីថ្នាក់បណ្ឌិត ត្រូវគ្រោងរៀបចំពិធីបវេសនកាលទៅតាមការសម្រេចរបស់គ្រឹះស្ថានបណ្តុះបណ្តាល។បវេសនកាលរួមមានទាំងការត្រូវរៀបចំបែងចែកនិស្សិតជ្រើសរើសថ្មីបញ្ចូលទៅតាមក្រុមមុខជំនាញនីមួយៗ របស់គ្រឹះស្ថានបណ្តុះបណ្តាល ឬ យ៉ាងហោចណាស់ ត្រឹមកម្រិតមហាវិទ្យាល័យឬវិទ្យាស្ថាន ដើម្បីជួយគ្រប់គ្រងការសិក្សា ស្រាវជ្រាវ និងការហ្វឹកហាត់ការងារផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រជាមួយក្រុមវិជ្ជាជីវៈដូចគ្នា។

# ជំពូកទី៣

# តម្រូវការធនធានសម្រាប់ទ្រទ្រង់ការបណ្តុះបណ្តាល

## ៣.១ ធនធានបណ្ណាល័យ

គ្រឹះស្ថានបណ្តុះបណ្តាលថ្នាក់បណ្ឌិតត្រូវមានបណ្ណាល័យប្រើប្រាស់ដែលក្នុងនោះមានទាំងឯកសារបោះពុម្ព និងឯកសារអេឡិចត្រូនិចដែលភ្ជាប់ជាបណ្តាញជាមួយបណ្ណាល័យដទៃទៀត ក្នុងនិងក្រៅប្រទេស សម្រាប់ជួយគាំទ្រក្នុងការស្រាវជ្រាវរកឯកសារពាក់ព័ន្ធយោងនិងគន្ថនិទ្ទេស។

គ្រឹះស្ថានបណ្តុះបណ្តាលត្រូវរៀបចំឱ្យមាននិក្ខេបបទថ្នាក់បណ្ឌិតដែលបានឆ្លងកាត់ការត្រួតពិនិត្យនិងវាយតម្លៃរួចថ្មីៗ ហើយមានគុណភាពសម្រាប់ផ្តល់ឱ្យនិស្សិតស្វែងយល់អំពីបច្ចុប្បន្នភាពនិងវិវឌ្ឍនភាពនៃការបណ្តុះបណ្តាលកម្រិតបណ្ឌិតនៅក្នុងតំបន់និងលើសកលលោក។

## ៣.២ ទីកន្លែងសម្រាប់អង្គុយសិក្សាស្រាវជ្រាវ/ធ្វើការ

បរិមាណនិស្សិតបណ្ឌិតដែលជ្រើសរើសនៅគ្រឹះស្ថានបណ្តុះបណ្តាលនីមួយៗ ត្រូវសមាមាត្រទៅនឹងទំហំទីកន្លែងដែលអាចបែងចែកឱ្យនិស្សិតអង្គុយសិក្សាស្រាវជ្រាវជារួមនិងជាបុគ្គលម្នាក់ៗនៅតាមក្រុមមុខជំនាញ។

### ៣.៣ ធនធានសារគមនាគមន៍និងបច្ចេកវិទ្យាព័ត៌មាន

គ្រឹះស្ថានបណ្តុះបណ្តាលកម្មវិធីថ្នាក់បណ្ឌិត ត្រូវមានធនធានសារគមនាគមន៍និងបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រាន់ ទាំងនៅក្នុងបណ្ណាល័យ ទាំងនៅកន្លែងសិក្សាស្រាវជ្រាវផ្សេងៗទៀតក្នុងបរិវេណគ្រឹះស្ថានរបស់ខ្លួន ដើម្បីជួយសម្រួល ដល់ដំណើរការស្រាវជ្រាវរបស់និស្សិត។

### ៣.៤ ធនធានសាស្ត្រាចារ្យ

សាស្ត្រាចារ្យចូលរួមបង្រៀន និងណែនាំក្នុងវគ្គសិក្សាថ្នាក់បណ្ឌិត ត្រូវតែជាអ្នកមានសញ្ញាបត្របណ្ឌិតដែលសកម្ម នាំមុខគេក្នុងការស្រាវជ្រាវទាក់ទងទៅនឹងវិស័យដែលខ្លួនកំពុងបង្រៀន និងណែនាំ ដើម្បីជាគុណប្រយោជន៍សំខាន់ ដែលសាស្ត្រាចារ្យនោះអាចផ្ទេរចំណេះដឹងនិងបទពិសោធន៍ស្រាវជ្រាវរបស់ខ្លួនទៅឱ្យនិស្សិតបានទាន់ពេលវេលានិងត្រឹមត្រូវ។ គ្រឹះស្ថានបណ្តុះបណ្តាលកម្មវិធីថ្នាក់បណ្ឌិតត្រូវមានផែនការសកម្មភាពច្បាស់លាស់ទុកជាមុនអំពីលទ្ធភាពធនធានសាស្ត្រាចារ្យបង្រៀននិងណែនាំរបស់ខ្លួនទៅតាមមុខជំនាញដែលគ្រោងបើក ជាពិសេសមានរៀបចំរចនាសម្ព័ន្ធតាមក្រុមមុខជំនាញបណ្តុះបណ្តាលនីមួយៗប្រចាំគ្រឹះស្ថាន។

### ៣.៥ ធនធានហិរញ្ញវត្ថុ

គ្រឹះស្ថានបណ្តុះបណ្តាលត្រូវរាយការណ៍អំពីលទ្ធភាពធនធានហិរញ្ញវត្ថុនិងផែនការប្រើប្រាស់លម្អិតសម្រាប់គាំទ្រដល់ដំណើរការកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតរបស់ខ្លួនឱ្យមានភាពរលូន មកក្រសួងអប់រំ យុវជន និងកីឡា ដោយមានឯកសារជាភស្តុតាងបញ្ជាក់ភ្ជាប់មកជាមួយទៅតាមករណី មុននឹងចាប់ផ្តើមជ្រើសរើសធ្វើការបណ្តុះបណ្តាល។ ធនធានហិរញ្ញវត្ថុទាំងនោះអាចបានមកពីប្រភពនានា ដូចជាការបង់ថ្លៃសិក្សារបស់និស្សិត អំណោយពីសប្បុរសជននិងមូលនិធិផ្សេងៗ ថវិកាឧបត្ថម្ភរបស់រាជរដ្ឋាភិបាល និង ដៃគូសហប្រតិបត្តិការជាតិនិងអន្តរជាតិ។

## ជំពូកទី៤

## កម្មវិធីបណ្តុះបណ្តាល

### ៤.១ គោលបំណង និង វត្ថុបំណងកម្មវិធីសិក្សា

#### ក. បណ្ឌិតស្រាវជ្រាវ

គោលបំណងចំបងនៃកម្មវិធីសិក្សាថ្នាក់បណ្ឌិតស្រាវជ្រាវគឺចង់ជំរុញឱ្យមានការរួមចំណែកថ្មីសំខាន់ដល់ចំណេះដឹងនៅក្នុងមុខជំនាញដែលបានជ្រើសរើសតាមរយៈការស្រាវជ្រាវ ទាំងមូលដ្ឋានទ្រឹស្តី ទាំងការអនុវត្ត។ ចំណុចសំខាន់មួយ នៃដំណើរការនេះគឺការបំពាក់បំប៉ននិស្សិតឱ្យចេះដោះស្រាយបញ្ហាស្មុគស្មាញនានាតាមការអនុវត្តវិធីសាស្ត្រ បច្ចេកទេស និងការវិភាគដោយឯករាជ។ និស្សិតនឹងមានឱកាសទទួលបាននូវជំនាញទាំងវិធីសាស្ត្រនិងបច្ចេកទេសស្រាវជ្រាវតាមរយៈកម្មវិធីសិក្សាល្អិតល្អន់ និងការស្រាវជ្រាវដែលមានការណែនាំ។

**វត្ថុបំណងកម្មវិធីសិក្សាគឺ៖**

ផ្តល់បរិស្ថានសិក្សាមួយដែលនិស្សិតនឹងបុរេសកម្មព្រមទាំងចេះផ្តួចផ្តើមគំនិតក្នុងការកំណត់រកអត្តសញ្ញាណ ការអនុវត្ត និងអភិវឌ្ឍប្រធានបទស្រាវជ្រាវរបស់ពួកគេ។

និស្សិតត្រូវបានចាប់បញ្ចូលទៅក្នុងសកម្មភាពនានាដែលបង្ហាញនូវតម្រូវការជាក់លាក់មួយចំនួន ដូចជា៖

- ការយល់ដឹងពីការងារបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវទាន់សម័យដ៏ស្មុគស្មាញ
- ការរួមចំណែកដល់មុខជំនាញដែលបានជ្រើសរើសតាមរយៈការផ្តល់គំនិតថ្មីៗ
- ការផ្លាស់ប្តូរ និងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវនានា។

អភិវឌ្ឍអភិក្រមផ្ទាល់ខ្លួននិស្សិតដើម្បីធ្វើការស្រាវជ្រាវ និង អភិវឌ្ឍគំនិតរបស់ពួកគេសំដៅសម្រេចឱ្យបាននូវលទ្ធផលស្រាវជ្រាវថ្មីៗហើយប្លែក។ បង្កើនសមត្ថភាពរបស់និស្សិតក្នុងការគ្រោងរៀបចំនិងអនុវត្តគម្រោងស្រាវជ្រាវទៅនឹងក្របខណ្ឌចំណេះដឹងតាមជំនាញដែលបានជ្រើសរើស។ ផ្តល់ឱ្យនិស្សិតនូវឱកាសដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការគិតត្រិះរិះពិចារណា និងវិភាគ។

### ខ. បណ្ឌិតវិជ្ជាជីវៈ

គោលបំណងកម្មវិធីសិក្សាថ្នាក់បណ្ឌិតវិជ្ជាជីវៈគឺ ៖

- រៀបចំនិស្សិតឱ្យមានលទ្ធភាពចូលរួមចំណែកប្រតិបត្តិយ៉ាងសំខាន់នៅក្នុងមុខវិជ្ជាជីវៈដែលគេបានជ្រើសរើសតាមរយៈការពង្រីកចំណេះដឹងនិងជំនាញរបស់និស្សិត
- ជំរុញនិស្សិតដែលជាអ្នកមានបទពិសោធន៍វិជ្ជាជីវៈឱ្យបង្កើនកម្រិតភាពជាអ្នកដឹកនាំនៅក្នុងមុខជំនាញដែលគេបានជ្រើសរើស និង
- អភិវឌ្ឍន៍ចំណេះដឹងទ្រឹស្តីនិងបំណិនវិជ្ជាជីវៈរបស់និស្សិត។

សម្រាប់កម្មវិធីសិក្សាថ្នាក់បណ្ឌិតវិជ្ជាជីវៈនេះ ភាគច្រើននៃបេក្ខជនជាអ្នកមានវិជ្ជាជីវៈធ្លាប់មានបទពិសោធន៍ដូចនេះកម្មវិធីសិក្សាត្រូវរៀបចំយ៉ាងណាដើម្បីឱ្យសមស្របទៅនឹងការចូលរួមនៃការងារវិជ្ជាជីវៈទាំងនេះ។

កម្មវិធីសិក្សាផ្តោតជាសំខាន់ទៅលើការពង្រឹងការប្រតិបត្តិវិជ្ជាជីវៈ អភិវឌ្ឍន៍បំណិនទូលំទូលាយអំពីភាពជាអ្នកដឹកនាំនិងការគ្រប់គ្រង ហើយនិង ការពង្រីកវិសាលភាពនៃចំណេះដឹងដែលផ្សារភ្ជាប់ទៅនឹងមុខជំនាញពាក់ព័ន្ធ។ លក្ខណៈប្រតិបត្តិនៃកម្មវិធីនេះត្រូវឱ្យសមស្របទៅនឹងវិធីសាស្ត្រស្រាវជ្រាវបែបសកម្មភាព ហើយអ្នកចូលរួមត្រូវបានទាមទារឱ្យធ្វើការស្រាវជ្រាវនូវទិដ្ឋភាពនានានៃការងារជំនាញ ដែលអាចនាំឆ្ពោះទៅរកការធ្វើឱ្យកាន់តែប្រសើរឡើងដល់ការប្រតិបត្តិវិជ្ជាជីវៈទាំងនោះ និងការរួមចំណែកបង្កើតចំណេះដឹងដែលទាក់ទងទៅនឹងវិស័យវិជ្ជាជីវៈនីមួយៗរបស់ពួកគេ។

កម្មវិធីសិក្សានេះនឹងជួយឱ្យនិស្សិតក្លាយជា ៖

- អ្នកដឹកនាំក្នុងការអភិវឌ្ឍគោលនយោបាយ និងនវានុវត្តន៍ដែលរួមចំណែកដល់ការរិះរកវិធីសាស្ត្រសម្រាប់ដំណោះស្រាយបញ្ហានានា ដោយប្រើប្រាស់បច្ចេកវិទ្យាថ្មី និង ការអនុវត្តវាដោយស្ទាត់ជំនាញ
- អ្នកមានចំណេះដឹងអំពីមូលដ្ឋានគ្រឹះនៃទ្រឹស្តី និងជាអ្នកមានបំណិនខ្ពស់ក្នុងទំនាក់ទំនងដល់គ្រប់កម្រិតសំដៅទទួលបានលទ្ធផលយ៉ាងល្អប្រសើរ
- អ្នកមានការទទួលខុសត្រូវខ្ពស់ចំពោះការងារវិជ្ជាជីវៈរបស់ពួកគេ។

## ៤.២ រយៈពេលសិក្សា និង បរិមាណសិក្សា

កម្មវិធីថ្នាក់បណ្ឌិតមានរយៈពេលសិក្សាពី បី(៣)ទៅប្រាំមួយ(៦)ឆ្នាំសម្រាប់ការសិក្សាពេញម៉ោង និង ពីបួន(៤)ទៅប្រាំបី(៨)ឆ្នាំសម្រាប់ការសិក្សាមិនពេញម៉ោង។ ប្រភេទកម្មវិធីសិក្សាពេញម៉ោងសំដៅចំពោះនិស្សិតដែលត្រៀមខ្លួនជាស្រេចប្រើប្រាស់ពេលវេលាពេញលេញក្នុងមួយសប្តាហ៍ សម្រាប់ការសិក្សាស្រាវជ្រាវរបស់ខ្លួន។ ប្រភេទកម្មវិធីសិក្សាមិនពេញម៉ោង សំដៅចំពោះនិស្សិតដែលមិនមានពេលវេលាពេញលេញក្នុងមួយសប្តាហ៍។

មុនចាប់ផ្តើមអនុវត្តកម្មវិធីសិក្សា គ្រឹះស្ថានបណ្តុះបណ្តាល ត្រូវកំណត់ជាស្រេចពីប្រភេទសិក្សាពេញម៉ោង និង មិនពេញម៉ោងសម្រាប់និស្សិតម្នាក់ៗ។

បរិមាណសិក្សាអប្បបរមានៃកម្មវិធីបណ្តុះបណ្តាលកម្រិតបណ្ឌិតនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលនានាក្នុងព្រះរាជាណាចក្រកម្ពុជាមានចំនួន៥៤ក្រេឌីតសិក្សា។ រូបភាពនៃការបណ្តុះបណ្តាលកម្រិតបណ្ឌិតត្រូវអនុវត្តជាសំខាន់ដោយ

វិធីស្វ័យសិក្សា និងស្រាវជ្រាវដោយមានការណែនាំ។ តម្លៃក្រេឌីតសិក្សាត្រូវរៀបចំដោយសមមូលទៅនឹងទំហំការងារសិក្សា ឬ ស្រាវជ្រាវ។

និស្សិតអាចស្នើទៅគ្រឹះស្ថានបណ្តុះបណ្តាលដើម្បីសុំការពន្យារពេលសិក្សានៅក្នុងករណីពិសេសដោយមានការយល់ព្រមពីក្រុមសាស្ត្រាចារ្យណែនាំ និង មានការឯកភាពពីក្រុមប្រឹក្សាវិទ្យាសាស្ត្ររបស់គ្រឹះស្ថានបណ្តុះបណ្តាល។ ការសុំពន្យារពេលនេះអាចធ្វើឡើងបានតែមួយដងគត់ ហើយត្រូវដាក់ពាក្យសុំពន្យារឱ្យបាន៦ខែមុនកាលបរិច្ឆេទបញ្ចប់។

## ៤.៣ រចនាសម្ព័ន្ធកម្មវិធីសិក្សាសម្រាប់បណ្ឌិតស្រាវជ្រាវ

បរិមាណសិក្សានេះត្រូវបានបែងចែកជាតម្លៃអប្បបរមាទៅតាមក្រុមប្រភេទសិក្សា ដូចខាងក្រោម៖

| | |
|---|---|
| - សិក្សាមុខវិជ្ជាបំពេញបន្ថែម | ៦ ក្រេឌីតសិក្សា |
| - សិក្សាមុខវិជ្ជាកម្រិតបណ្ឌិត | ៦ ក្រេឌីតសិក្សា |
| - សិក្សាមុខវិជ្ជាតម្រង់ទិសនិងការប្រឡងទូទៅ | ៩ ក្រេឌីតសិក្សា |
| - ការពារគម្រោងស្រាវជ្រាវពិស្តារ | ៣ ក្រេឌីតសិក្សា |
| - ការចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិ ឬ កម្រិតអន្តរជាតិ | ៦ ក្រេឌីតសិក្សា - |
| - ការចូលរួមវេទិកាវិទ្យាសាស្ត្រពាក់ព័ន្ធ | ៣ ក្រេឌីតសិក្សា |
| - ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួន | ៣ ក្រេឌីតសិក្សា |
| - និក្ខេបបទ | ១៨ ក្រេឌីតសិក្សា |
| សរុប | **៥៤** ក្រេឌីតសិក្សា |

## ៤.៤ រចនាសម្ព័ន្ធកម្មវិធីសិក្សាសម្រាប់បណ្ឌិតវិជ្ជាជីវៈ

បរិមាណសិក្សានេះត្រូវបានបែងចែកជាតម្លៃអប្បបរមាទៅតាមក្រុមប្រភេទសិក្សា ដូចខាងក្រោម៖

| | |
|---|---|
| - សិក្សាមុខវិជ្ជាបំពេញបន្ថែម | ៦ ក្រេឌីតសិក្សា |
| - សិក្សាមុខវិជ្ជាកម្រិតបណ្ឌិត | ១៥ ក្រេឌីតសិក្សា |
| - សារណាបទពិសោធន៍វិជ្ជាជីវៈ | ៦ ក្រេឌីតសិក្សា |
| - ការពារគម្រោងស្រាវជ្រាវពិស្តារ | ៣ ក្រេឌីតសិក្សា |
| - ការចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិ ឬ កម្រិតអន្តរជាតិ | ៦ ក្រេឌីតសិក្សា |
| - ការចូលរួមវេទិកាវិទ្យាសាស្ត្រពាក់ព័ន្ធ | ៣ ក្រេឌីតសិក្សា |
| - ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួន | ៣ ក្រេឌីតសិក្សា |
| - និក្ខេបបទ | ១២ ក្រេឌីតសិក្សា |
| សរុប | **៥៤** ក្រេឌីតសិក្សា |

## ៤.៥ ការសិក្សាមុខវិជ្ជាបំពេញបន្ថែម និង ការប្រឡង

ការសិក្សាមុខវិជ្ជាបំពេញបន្ថែមត្រូវធ្វើឡើងនៅខាងដើមនៃឆ្នាំសិក្សាដំបូង។ មហាវិទ្យាល័យ/វិទ្យាស្ថាន ឬក្រុមមុខជំនាញត្រូវផ្អែកលើសំណុំលិខិតនិងប្រវត្តិសិក្សារបស់និស្សិតដែលឱ្យចូលរៀន ដើម្បីដាក់ចេញនូវមុខវិជ្ជាចាំបាច់សម្រាប់បំពេញឱ្យកម្រិតមូលដ្ឋានបរិញ្ញាបត្រនិងបរិញ្ញាបត្រជាន់ខ្ពស់របស់ពួកគេ ប្រគល់ឱ្យនាយកគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតសម្រេច។

ក. មុខវិជ្ជាបំពេញបន្ថែមគឺជាបណ្តាមុខវិជ្ជាទាំងឡាយណានៅកម្មវិធីបរិញ្ញាបត្រឬបរិញ្ញាបត្រជាន់ខ្ពស់ ដែលនិស្សិតមិនបានឆ្លងកាត់។ មុខវិជ្ជាសិក្សាទាំងនេះសំដៅឱ្យនិស្សិតមានចំណេះដឹងមូលដ្ឋានរឹងមាំ និងកម្រិតមុខជំនាញ គ្រប់គ្រាន់សម្រាប់អនុវត្តបាននូវភារកិច្ចស្រាវជ្រាវជានិស្សិតថ្នាក់បណ្ឌិត។ ចំពោះនិស្សិតដែលមានបរិញ្ញាបត្រជាន់ខ្ពស់ដែរ ប៉ុន្តែជានិស្សិតមិនធ្វើនិក្ខេបបទមុខវិជ្ជាបំពេញបន្ថែមអាចជាបណ្តាមុខវិជ្ជាពាក់ព័ន្ធនានា និងវិធីសាស្ត្រស្រាវជ្រាវដែលពុំ ទាន់បានសិក្សាស៊ីជម្រៅនៅកម្រិតបរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ ។

ខ. ចំពោះនិស្សិតដែលមានបរិញ្ញាបត្រជាន់ខ្ពស់ ដោយសរសេរនិក្ខេបបទ ហើយមានជំនាញប្រហាក់ប្រហែលគ្នា ឬមិនដូចគ្នាទៅនឹងជំនាញសិក្សាថ្នាក់បណ្ឌិត ប្រធានក្រុមមុខជំនាញនិងព្រឹទ្ធបុរសមហាវិទ្យាល័យសហការគ្នាដោយប្រៀបធៀបមុខវិជ្ជារបស់ពួកគេដែលបានរៀននៅបរិញ្ញាបត្រ និងបរិញ្ញបត្រជាន់ខ្ពស់ ដើម្បីកំណត់អំពីមុខវិជ្ជាបំពេញបន្ថែម ដែលត្រូវឱ្យសិក្សា។

គ. នៅក្នុងករណីពិនិត្យប្រៀបធៀបថាចាំបាច់ បើកម្មវិធីបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រនិងបរិញ្ញាបត្រជាន់ខ្ពស់របស់និស្សិតនៅមានកង្វះចន្លោះ ប្រធានក្រុមមុខជំនាញត្រូវស្នើតាមរយៈប្រធានមហាវិទ្យាល័យទៅក្រុមប្រឹក្សាវិទ្យាសាស្ត្រអំពីមុខវិជ្ជាទាំងឡាយដែលត្រូវឱ្យនិស្សិតបំពេញបន្ថែម។

ឃ. លើមូលដ្ឋានស្នើរបស់ប្រធានក្រុមមុខជំនាញ តាមរយៈប្រធានមហាវិទ្យាល័យ ឬវិទ្យាស្ថាន ប្រធានក្រុមប្រឹក្សាវិទ្យាសាស្ត្ររបស់គ្រឹះស្ថានបណ្តុះបណ្តាលសម្រេចអំពីមុខវិជ្ជាសិក្សាឱ្យនិស្សិតបំពេញ បន្ថែមទៅតាមករណី ក ខ ឬគ។

បរិមាណសិក្សាសម្រាប់ក្រុមមុខវិជ្ជានេះមាន កម្រិតអប្បបរមាប្រាំមួយ(៦)ក្រេឌីត។ រូបភាពសិក្សាអាចឱ្យនិស្សិតស្វ័យសិក្សា ឬ ចូលសិក្សាជាមួយនឹងថ្នាក់ដែលមានស្រាប់កំពុងដំណើរការ រួចហើយត្រូវប្រឡងយកពិន្ទុដាច់ដោយឡែកផ្ទាល់ខ្លួនឬជាមួយនឹងថ្នាក់ដែលខ្លួនចូលសិក្សា។ ពិន្ទុទទួលបានពីការសិក្សាមុខវិជ្ជានីមួយៗមិនត្រូវឱ្យក្រោម៧០ភាគរយ។

## ៤.៦ ការសិក្សាមុខវិជ្ជាកម្រិតបណ្ឌិត និង ការប្រឡង

ការសិក្សាមុខវិជ្ជាកម្រិតបណ្ឌិតរួមមាន៖ មុខវិជ្ជារួម និង មុខវិជ្ជាមុខជំនាញ ដែលត្រូវបានអនុវត្តនៅក្នុងឆ្នាំសិក្សាទី១ និងអាចបន្តទៅឆ្នាំសិក្សាទី២។ នាយកគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិត ត្រូវរៀបចំអំពីផែនការសិក្សាមុខវិជ្ជារួម និងមុខវិជ្ជាមុខជំនាញ។ ផ្នែក ឬ ការិយាល័យទទួលបន្ទុកកម្មវិធីថ្នាក់បណ្ឌិត ត្រូវត្រៀមរៀបចំលក្ខខណ្ឌចាំបាច់សម្រាប់បម្រើឱ្យថ្នាក់រៀនទាំងនេះទៅតាមផែនការសិក្សាដែលបានកំណត់។

ផ្នែក ឬ ការិយាល័យគ្រប់គ្រងកម្មវិធីថ្នាក់បណ្ឌិត ត្រូវរៀបចំការបង្រៀននិងការវាយតម្លៃលទ្ធផលសិក្សាសម្រាប់មុខវិជ្ជារួមទាំងអស់របស់និស្សិតទៅតាមផែនការសិក្សារបស់គ្រឹះស្ថាន។

មហាវិទ្យាល័យ/វិទ្យាស្ថាន ឬ ក្រុមមុខជំនាញត្រូវរៀបចំការបង្រៀននិងការវាយតម្លៃលទ្ធផលសិក្សាមុខវិជ្ជាមុខជំនាញទាំងអស់របស់និស្សិតទៅតាមផែនការសិក្សារបស់គ្រឹះស្ថាន រួចហើយបញ្ជូនលទ្ធផលសិក្សាទាំងនោះទៅឱ្យផ្នែក ឬ ការិយា ល័យគ្រប់គ្រងកម្មវិធីថ្នាក់បណ្ឌិតរក្សាទុក។

លទ្ធផលប្រឡងវាយតម្លៃសម្រាប់ការសិក្សាមុខវិជ្ជាកម្រិតបណ្ឌិតរបស់និស្សិតម្នាក់ៗ មិនត្រូវស្ថិតនៅក្រោមពិន្ទុ ៧០%ជាដាច់ខាត។

## ៤.៧ ការសិក្សាមុខវិជ្ជាតម្រង់ទិសបណ្ឌិត និងការប្រឡង

គណៈកម្មការសាស្ត្រាចារ្យណែនាំនិង និស្សិតត្រូវបញ្ជូនលិខិតជាលាយលក្ខណ៍អក្សរលើកឡើងអំពីមុខវិជ្ជាតម្រង់ទិសបណ្ឌិតចំនួនបី(៣)ជូនមហាវិទ្យាល័យ/វិទ្យាស្ថាន ក្រុមមុខជំនាញជ្រាបយ៉ាងយូរ១ឆ្នាំក្រោយពេលចុះឈ្មោះសិក្សាកម្ម វិធីថ្នាក់បណ្ឌិតជាផ្លូវការ។ មុខវិជ្ជាតម្រង់ទិសនីមួយៗត្រូវមាន៖ ឈ្មោះមុខវិជ្ជាតម្រង់ទិស គម្រោងខ្លឹមសារទូទៅសំខាន់ៗ សាស្ត្រាចារ្យណែនាំវិទ្យាសាស្ត្រ និងផែនការអនុវត្ត។

មហាវិទ្យាល័យ/វិទ្យាស្ថាន ឬ ក្រុមមុខជំនាញពិនិត្យនិងឯកភាពលើសំណើមុខវិជ្ជាតម្រង់ទិសបណ្ឌិតរួចហើយត្រូវបញ្ជូនខ្លឹមសារទាំងនោះនិងលិខិតស្នើសុំជាផ្លូវការ តាមរយៈផ្នែក ឬ ការិយាល័យគ្រប់គ្រងកម្មវិធីថ្នាក់បណ្ឌិត ទៅឱ្យនាយកគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតធ្វើសេចក្តីសម្រេចនិងចុះហត្ថលេខាអំពីមុខវិជ្ជាតម្រង់ទិសទាំងនោះសម្រាប់និស្សិតម្នាក់ៗ។

ការបង្កើតអនុគណៈកម្មការកំណែវិញ្ញាសាមុខវិជ្ជាតម្រង់ទិសបណ្ឌិត៖

- យ៉ាងយូរមួយខែមុនពេលនិស្សិតឡើងធ្វើបទបង្ហាញអំពីមុខវិជ្ជាតម្រង់ទិស មហាវិទ្យាល័យ/វិទ្យាស្ថាន ឬក្រុមមុខជំនាញត្រូវផ្ញើសំណៅសរសេរមុខវិជ្ជាតម្រង់ទិសទាំងបី(៣)មុខរបស់និស្សិត រួមជាមួយបញ្ជីឈ្មោះស្នើរៀបចំអនុគណៈកម្មការកំណែមុខវិជ្ជាតម្រង់ទិសទាំងបី(៣)មុខដល់ការិយាល័យគ្រប់គ្រងកម្មវិធីថ្នាក់បណ្ឌិត។

-ការិយាល័យគ្រប់គ្រងកម្មវិធីថ្នាក់បណ្ឌិតត្រូវព្រៀងសេចក្តីសម្រេចបង្កើតអនុគណៈកម្មការកំណែមុខវិជ្ជាតម្រង់ទិសដើម្បីឱ្យនាយកគ្រប់គ្រងថ្នាក់បណ្ឌិតចុះហត្ថលេខា។ មុខវិជ្ជាតម្រង់ទិសនីមួយៗអាចមានអនុគណៈកម្មការកំណែដោយឡែក ដែលមានសមាសភាពបី(៣)រូប។ សាស្ត្រាចារ្យណែនាំមិនត្រូវបានអនុញ្ញាតឱ្យធ្វើជាប្រធាន ឬ លេខាកត់ត្រារបស់អនុគណៈកម្មការនេះឡើយ។

ការរៀបចំកំណែមុខវិជ្ជាតម្រង់ទិសបណ្ឌិត៖

- ក្រោយពេលមានលិខិតឧទ្ទេសនាមបង្កើតអនុគណៈកម្មការកំណែមុខវិជ្ជាតម្រង់ទិសដែលចុះហត្ថលេខាដោយនាយកគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតរួចមក មហាវិទ្យាល័យ/វិទ្យាស្ថាន ឬ ក្រុមមុខជំនាញត្រូវផ្ញើលិខិតអញ្ជើញ លិខិតឧទ្ទេសនាម និងសំណៅសរសេរមុខវិជ្ជាតម្រង់ទិសឱ្យសមាជិកអនុគណៈកម្មការនីមួយៗដើម្បីត្រៀមរៀបចំនូវបែបបទចាំបាច់នៅពេលប្រជុំកំណែមុខវិជ្ជាតម្រង់ទិស។

- សំណុំឯកសារត្រៀមសម្រាប់ពេលប្រជុំកំណែមុខវិជ្ជាតម្រង់ទិសរួមមាន៖ គំរូសាលាបត្រដែលត្រូវបំពេញនៅពេលការពារមុខវិជ្ជាតម្រង់ទិស សំណៅសរសេរមុខវិជ្ជាតម្រង់ទិសបណ្ឌិតទាំងបី(៣)របស់និស្សិត។

- ការប្រជុំធ្វើកំណែមុខវិជ្ជាតម្រង់ទិសបណ្ឌិតត្រូវធ្វើឡើងទៅតាមទីកន្លែងដែលបានកំណត់ដោយមហាវិទ្យាល័យ/វិទ្យាស្ថាន ឬ ក្រុមមុខជំនាញ ក្រោមការសម្របសម្រួលរបស់ផ្នែក ឬ ការិយាល័យគ្រប់គ្រងកម្មវិធីថ្នាក់បណ្ឌិត។

- លំដាប់លំដោយនៅពេលប្រជុំមុខវិជ្ជាតម្រង់ទិសមានដូចខាងក្រោម៖

+ ប្រកាសហេតុដោយមហាវិទ្យាល័យ/វិទ្យាស្ថាន ឬក្រុមមុខជំនាញ អានលិខិតឧទ្ទេសនាមរបស់អនុគណៈកម្មការប្រគល់ភារកិច្ចសម្របសម្រួលដល់ប្រធានអនុគណៈកម្មការ

+ និស្សិតឡើងបង្ហាញមុខវិជ្ជាតម្រង់ទិសក្នុងរយៈពេលមិនលើសពី៣០នាទី

+ សមាជិកអនុគណៈកម្មការនិងអ្នកចូលរួមចោទសំណួរ ផ្លាស់ប្តូរយោបល់ ពិភាក្សារួមជាមួយនិស្សិត

+ ផ្អែកលើគុណភាពនៃការបង្ហាញរបស់និស្សិត ការស្តែងចេញនូវកម្រិតយល់ដឹងនិងចំណេះដឹងរបស់និស្សិតឆ្លងតាមការផ្លាស់ប្តូរនិងពិភាក្សាវិទ្យាសាស្ត្រ អនុគណៈកម្មការនឹងវាយតម្លៃនិងផ្តល់ពិន្ទុ។ ពិន្ទុវាយតម្លៃដែលជាប់ដោយជោគជ័យគឺចាប់ពី៧០%ឡើងទៅ។

-ក្នុងករណីការការពារមុខវិជ្ជាតម្រង់ទិសមិនទទួលបានជោគជ័យ និស្សិតត្រូវការពារមុខវិជ្ជាតម្រង់ទិសបណ្ឌិតនេះឡើងវិញក្នុងរយៈពេលយ៉ាងឆាប់បំផុតមួយខែគិតចាប់ពីថ្ងៃការពារលើកមុន។

### ៤.៨ ការប្រឡងទូទៅ

នៅពេលដែលនិស្សិតបានបំពេញដោយជោគជ័យតាមការស្ទង់សិក្សាមុខវិជ្ជាតម្រង់ទិស និស្សិតត្រូវធ្វើការប្រឡងទូទៅមួយ ដោយការសរសេរសារណាត្រិះរិះនិងសំយោគ ដែលក្នុងនោះមាន ៖

- បង្ហាញការយល់ដឹងពីឯកសារពាក់ព័ន្ធបច្ចុប្បន្ន និងការស្រាវជ្រាវថ្មីៗក្នុងមុខជំនាញដែលពួកគេបានជ្រើសរើសប្រធានបទតាមរយៈការសរសេរសារណា
- បង្ហាញពីលទ្ធផលសំយោគឯកសារពាក់ព័ន្ធនានាដែលបម្រុងនឹងយកមកប្រើប្រាស់ក្នុងគម្រោងស្រាវជ្រាវរបស់ពួកគេ តាមរយៈការធ្វើបទបង្ហាញជាផ្លូវការមួយ ទៅកាន់អ្នករួមវិជ្ជាជីវៈនិងក្រុមសាស្ត្រាចារ្យណែនាំ
- រូបភាពនៃការប្រឡងនេះគឺធ្វើឡើងដោយគួបផ្សំការសរសេរជាសារណាផង និងការឡើងបង្ហាញផ្ទាល់មាត់ផង
- មហាវិទ្យាល័យ/ វិទ្យាស្ថាន ឬ ក្រុមមុខជំនាញត្រូវរៀបចំអនុគណៈកម្មការ ដែលមានសមាសភាពបី(៣)រូបសម្រាប់វាយតម្លៃការប្រឡងទូទៅនេះ
- ពិន្ទុវាយតម្លៃដែលជាប់ដោយជោគជ័យ គឺចាប់ពី៧០% ឡើងទៅ។

## ៤.៩ ការរៀបចំសារណាបទពិសោធន៍វិជ្ជាជីវៈ

សារណាបទពិសោធន៍វិជ្ជាជីវៈ គឺជារបាយការណ៍វិទ្យាសាស្ត្រមួយបានមកពីការប្រតិបត្តិរបស់និស្សិតនៅស្ថាប័នណាមួយក្នុងរយៈពេលមួយជាកំណត់។ វាមានទម្រង់ជារបាយការណ៍ស្រាវជ្រាវផង និងជាបទពិសោធន៍ដកស្រង់ពីការប្រតិបត្តិវិជ្ជាជីវៈផង។

គោលបំណងនៃសារណាបទពិសោធន៍វិជ្ជាជីវៈនេះ គឺហ្វឹកហាត់និស្សិតឱ្យចេះរៀបចំធ្វើការសង្កេតវិទ្យាសាស្ត្រលើកនូវចំណោទបញ្ហាដើម្បីអភិវឌ្ឍ ឬលើកកម្ពស់វិជ្ជាជីវៈរបស់ខ្លួន សំយោគទ្រឹស្តីពាក់ព័ន្ធនិងរៀបចំជាបញ្ញត្តិកម្មណាមួយឡើង ហើយនិងការស្នើឡើងនូវវិធីសាស្ត្រគ្រោងដោះស្រាយ។

ការប្រឡងត្រូវធ្វើឡើងដោយគួបផ្សំការសរសេរជាសារណាមួយឡើងប្រហាក់ប្រហែលសាបសិបទំព័រ ហើយនិងការឡើងបង្ហាញដោយផ្ទាល់មាត់ចំពោះអនុគណៈកម្មការវាយតម្លៃមួយដែលមានសមាសភាពបី(៣)រូប រៀបចំឡើងដោយមហាវិទ្យាល័យ/វិទ្យាស្ថាន ឬ ក្រុមមុខជំនាញក្រោមការសម្របសម្រួលជាមួយការិយាល័យ ឬ ផ្នែកគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិត។

## ៤.១០ ការស្រាវជ្រាវដោយមានការណែនាំ

និស្សិតថ្នាក់បណ្ឌិតទាំងពីរប្រភេទ ត្រូវចាប់ផ្តើមកម្មវិធីស្រាវជ្រាវដូចដែលបានរៀបរាប់ក្នុងសំណើស្រាវជ្រាវ។ និស្សិតត្រូវជួបពិភាក្សាជាមួយសាស្ត្រាចារ្យណែនាំគោលជាប្រចាំ។ ពួកគេក៏ត្រូវជួបពិភាក្សាជាមួយនឹងសមាជិកដទៃទៀតនៃគណៈកម្មការសាស្ត្រាចារ្យ ណែនាំទៅតាមសេចក្តីត្រូវការជាក់ស្តែង។ និស្សិតត្រូវធ្វើរបាយការណ៍ត្រួតពិនិត្យការងាររបស់ខ្លួនជាផ្លូវការក្នុងរយៈពេល៦ ខែម្តងជាទៀងទាត់ បញ្ជូនទៅឱ្យនាយកគ្រប់គ្រងកម្មវិធីថ្នាក់បណ្ឌិត តាមរយៈសាស្ត្រាចារ្យណែនាំគោល។ និស្សិតត្រូវធ្វើការពិភាក្សាពីលទ្ធផលនៃការងារក្នុងរយៈពេល៦ខែមុន ដោយធ្វើការប្រៀបធៀបជាមួយផែនការស្រាវជ្រាវ ហើយត្រូវរៀបចំផែនការសម្រាប់រយៈពេល៦ខែបន្ទាប់ច្បាស់លាស់ ដោយមានគោលដៅនិងលទ្ធផលរំពឹងទុកដែលអាចវាស់បាន។

សាស្ត្រាចារ្យណែនាំគោល ត្រូវផ្តល់ការវាយតម្លៃជាលាយល័ក្សអក្សរអំពីដំណើរការសិក្សាស្រាវជ្រាវនិងភាពជឿនលឿនរបស់និស្សិតក្នុងរយៈពេល៦ខែម្តងជាទៀងទាត់ ផ្ញើជូនទៅឱ្យនាយកគ្រប់គ្រងកម្មវិធីថ្នាក់បណ្ឌិត ហើយចម្លងជូនដល់និស្សិតផងដែរ។

## ៤.១១ គម្រោងស្រាវជ្រាវពិស្តារ

ការតម្រូវឱ្យមានគម្រោងស្រាវជ្រាវពិស្តារមួយសមស្របនិងអាចជឿទុកចិត្តបាន មុននឹងឱ្យចាប់ផ្តើមធ្វើពិសោធន៍ស្រាវជ្រាវ ឬ ការចុះផ្ទាល់ដល់កន្លែងឬការដ្ឋានស្រាវជ្រាវ គឺជាយន្តការមួយសម្រាប់រួមចំណែកធ្វើឱ្យនិស្សិតកាន់តែមានភាពជឿជាក់ និងភាពម្ចាស់ការលើខ្លួនឯងក្នុងការបន្តការស្រាវជាវឆ្ពោះទៅរកគោលដៅពិតប្រាកដ ហើយនិងការធានាគុណភាព

ការស្រាវជ្រាវផងដែរ។ មុននឹងឈានទៅចាប់ផ្តើមដំណាក់ស្រាវជ្រាវសំខាន់របស់និក្ខេបបទ បេក្ខបណ្ឌិតចាំបាច់ត្រូវមានគម្រោងស្រាវជ្រាវពិស្តារមួយដែលអាចសង្ឃឹមបាននៅក្នុងដៃជាផែនទី ដើម្បីអាចជៀសវាងការខ្ជះខ្ជាយពេលវេលា និងខាតបង់ទុនច្រើន ហើយលទ្ធផលសង្ឃឹមអាចយកជាការបាន។

ការឆ្លងកាត់បានដោយជោគជ័យការការពារគម្រោងស្រាវជ្រាវពិស្តារ ត្រូវបានគិតបញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលសមមូលនឹង៣ក្រេឌីតសិក្សា។ ការទទួលស្គាល់ត្រូវធ្វើឡើងដោយកំណត់ហេតុនៅពេលការពារ ដែលមានចុះហត្ថលេខាដោយសាស្ត្រាចារ្យណែនាំគោលជាប្រធានគណៈកម្មការ និង មានការឯកភាពពីផ្នែកបណ្តុះបណ្តាលកម្មវិធីថ្នាក់បណ្ឌិត។

## ៤.១២ និក្ខេបបទបណ្ឌិត

ប្រធានបទនិក្ខេបបទស្រាវជ្រាវរបស់បេក្ខបណ្ឌិតម្នាក់ៗ ត្រូវមានការទទួលស្គាល់ពីគណៈកម្មាធិការជាតិរៀបចំគោលការណ៍ណែនាំការបណ្តុះបណ្តាលថ្នាក់បណ្ឌិត។

និក្ខេបបទបណ្ឌិតត្រូវតែជាស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រដើមដំបូងគេកម្រិតខ្ពស់ ច្នៃប្រឌិតក្នុងវិស័យស្រាវជ្រាវដែលមានការរួមចំណែកអំពីទ្រឹស្តី ដែលជាចំណេះដឹងឬដំណោះស្រាយថ្មីមានតម្លៃសម្រាប់ការអភិវឌ្ឍន៍ លើកកម្ពស់ចំណេះដឹងវិទ្យាសាស្ត្រក្នុងវិស័យស្រាវជ្រាវ ឬ វិធីដោះស្រាយប្រកបដោយភាពច្នៃប្រឌិតនូវរាល់បញ្ហាដែលបានចោទឡើងចំពោះមុខជំនាញវិទ្យាសាស្ត្រ ឬ ការជាក់ស្តែងសង្គម។

ខ្លឹមសារនិក្ខេបបទបណ្ឌិតត្រូវមានបរិមាណពី១០០ទៅ៣០០ទំព័រA4 ដែលនៅក្នុងនោះ ៥០%(ហាសិបភាគរយ) គឺជាការបង្ហាញអំពីលទ្ធផលស្រាវជ្រាវ ការវិភាគ សំយោគឯកសារពាក់ព័ន្ធ និងការបកស្រាយផ្ទាល់របស់បេក្ខជន។

## ៤.១៣ តម្រូវការភាសាអន្តរជាតិ និង មូលដ្ឋានគ្រឹះព័ត៌មានវិទ្យាសម្រាប់ការស្រាវជ្រាវ

### ក. តម្រូវការកម្រិតភាសាអន្តរជាតិ

នៅពេលដាក់សំណុំលិខិតសុំជ្រើសរើសបេក្ខបណ្ឌិតត្រូវមានវិញ្ញាបនបត្រឬសញ្ញាបត្រភាសាអន្តរជាតិតាម ប្រការណាមួយដូចខាងក្រោម៖

ក១. មានបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ពីប្រទេសក្រៅដែលប្រើភាសាអង់គ្លេសក្នុងការបណ្តុះបណ្តាលឬភាសាបរទេសណាមួយទៀតសមស្របទៅនឹងតម្រូវការរបស់មុខជំនាញបណ្តុះបណ្តាលតាមការសម្រេចរបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រ។

ក២. មានបរិញ្ញាបត្រ និង បរិញ្ញាបត្រជាន់ខ្ពស់នៅក្នុងប្រទេសដែលភាសាប្រើប្រាស់ក្នុងការបណ្តុះបណ្តាលជាភាសាអង់គ្លេសមិនឆ្លងកាត់អ្នកបកប្រែ ឬភាសាអន្តរជាតិណាមួយសមស្របទៅនឹងតម្រូវការមុខជំនាញបណ្តុះបណ្តាលតាមការសម្រេចរបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រ។

ក៣. មានបរិញ្ញាបត្រភាសាអង់គ្លេស ឬភាសាអន្តរជាតិណាមួយសមស្របទៅនឹងតម្រូវការមុខជំនាញបណ្តុះបណ្តាល តាមការសម្រេចរបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រ។

ក៤. មានវិញ្ញាបនបត្រភាសាអង់គ្លេស TOEFL IBT ៦១ ពិន្ទុ ឬ TOEFL ៥០០ ឬ TOEFL ITP ៥០០ ពិន្ទុ ឬ IELTS ៥.០ ឡើងទៅ ឬ សមមូល។

កម្រិតភាសាអន្តរជាតិសមមូលត្រូវបានកំណត់តាមភាពជាក់ស្តែង និង ទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។

**ខ. កម្រិតប្រើប្រាស់មូលដ្ឋានបច្ចេកវិទ្យាព័ត៌មានសម្រាប់ការស្រាវជ្រាវ**

តម្រូវការឱ្យមានវិញ្ញាបនបត្របញ្ជាក់ពីកម្រិតនៃការប្រើប្រាស់មូលដ្ឋានគ្រឹះព័ត៌មានវិទ្យាសម្រាប់ការស្រាវជ្រាវ (Word, Excel, PowerPoint និង Internet search) ។

## ៤.១៤ ការចូលរួមសិក្ខាសាលា

ការចូលរួមសិក្ខាសាលា ឬ វេទិកាវិទ្យាសាស្ត្រពាក់ព័ន្ធនានា ក្នុងនិងក្រៅប្រទេស គឺដើម្បីស្វែងយល់នូវចំណេះដឹងបន្ថែមដែលទាក់ទងនឹងជំនាញរបស់ខ្លួន។ វាជាករណីចាំបាច់របស់និស្សិតថ្នាក់បណ្ឌិតម្នាក់ៗ ក្នុងការទម្លាប់និងផ្សាំខ្លួនទៅក្នុងសហគមន៍អ្នកស្រាវជ្រាវ។ ការចូលរួមសិក្ខាសាលានេះត្រូវបានគិតជាចំនួន៣ក្រេឌីតសិក្សាសរុប ចំពោះការចូលរួមបាន៦លើកនៅក្នុងប្រទេស ឬ ៣លើកនៅក្រៅប្រទេស សម្រាប់រាប់បញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតតាមការកំណត់របស់គ្រឹះស្ថាននីមួយៗ។ ការចូលរួមវេទិកានៅក្រៅប្រទេស១លើកសមមូលនឹងការចូលរួមនៅក្នុងប្រទេស ២ លើក។ ការទទួលស្គាល់ការចូលរួមទាំងនេះត្រូវមានលិខិតបញ្ជាក់ពីអ្នករៀបចំ ឬ ឯកសារជាភស្តុតាងអ្វីមួយដែលអាចយកជាការបាន។

## ៤.១៥ ការធ្វើសិក្ខាសាលា

ការធ្វើសិក្ខាសាលា គឺការឡើងបង្ហាញនូវលទ្ធផលនិងចំណេះដឹងដែលបានមកពីការស្រាវជ្រាវរបស់ខ្លួន ដើម្បីស្វែងរកភាពចន្លោះប្រហោងនិងចំណុចខ្សោយរបស់និក្ខេបបទ តាមរយៈការរិះគន់ សំណួរនិងការបកស្រាយ ហើយនិងអនុសាសន៍ពីក្រុមអ្នកជំនាញពាក់ព័ន្ធ សំដៅធ្វើឱ្យនិក្ខេបបទកាន់តែមានភាពសុក្រឹត និង ឆ្ពោះទៅរកការបញ្ចប់ដោយជោគជ័យបាន។ វាជាករណីប្រតិបត្តិចាំបាច់របស់និស្សិតថ្នាក់បណ្ឌិតម្នាក់ៗ។ ការធ្វើសិក្ខាសាលានេះត្រូវបានគិតជាចំនួន៣ក្រេឌីត សម្រាប់ការធ្វើសិក្ខាសាលាឱ្យបាន២ដងមុនការឡើងការពារបញ្ចប់ ដើម្បីបញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិត តាមការកំណត់របស់គ្រឹះស្ថាននីមួយៗ។ ការកំណត់ពេលវេលាធ្វើសិក្ខាសាលានីមួយៗត្រូវមានការយល់ព្រមឯកភាពពីសាស្ត្រាចារ្យណែនាំ និង ជួយជ្រោមជ្រែងពីក្រុមមុខជំនាញ។ ការបានធ្វើសិក្ខាសាលានេះឡើង ត្រូវបានទទួលស្គាល់ដោយកំណត់ហេតុពេលឡើងបង្ហាញ ដែលរៀបចំដោយគណៈកម្មការសាស្ត្រាចារ្យណែនាំនិងឯកភាពពីផ្នែកឬការិយាល័យទទួលបន្ទុកកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិត។

## ៤.១៦ ការរៀបចំអត្ថបទចុះផ្សាយទស្សនាវដ្តីវិទ្យាសាស្ត្រឬវិជ្ជាជីវៈ

ក្រោយពីបានធ្វើសិក្ខាសាលាដើម្បីបង្ហាញនូវចំណេះដឹងដែលបានមកពីការស្រាវជ្រាវទាក់ទងនឹងជំនាញរបស់ខ្លួនរួចហើយ បេក្ខបណ្ឌិតម្នាក់ៗត្រូវរៀបចំបទបង្ហាញនោះជាអត្ថបទសម្រាប់ចុះផ្សាយក្នុងទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រ ឬ វិជ្ជាជីវៈកម្រិតជាតិឬអន្តរជាតិ។ ការចុះអត្ថបទផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រត្រូវបានគិតជាចំនួនប្រាំមួយ(៦)ក្រេឌីតបញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតតាមការកំណត់របស់គ្រឹះស្ថាននីមួយៗ។ ការចុះផ្សាយអត្ថបទស្រាវជ្រាវបានមួយអត្ថបទក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រអន្តរជាតិសមមូលនឹងការចុះផ្សាយនៅទស្សនាវដ្តីវិទ្យាសាស្ត្រកម្រិតជាតិចំនួនពីរអត្ថបទ ដែលស្មើនឹងប្រាំមួយ(៦)ក្រេឌីត។

ទស្សនាវដ្តីវិទ្យាសាស្ត្រឬវិជ្ជាជីវៈកម្រិតជាតិ គឺជាទស្សនាវដ្តីក្នុងស្រុកដែលចុះផ្សាយនូវអត្ថបទស្រាវជ្រាវដោយមានក្រុមអ្នកវិទ្យាសាស្ត្រ ឬវិជ្ជាជីវៈជាទៀងទាត់សម្រាប់ការត្រួតពិនិត្យនិងជ្រើសរើសដោយឯករាជដើម្បីចុះផ្សាយ។ ទស្សនាវដ្តីកម្រិតអន្តរជាតិ គឺជាទស្សនាវដ្តីវិទ្យាសាស្ត្រឬវិជ្ជាជីវៈក្រៅប្រទេស តំបន់ ឬសកលលោកដែលមានក្រុមបណ្ណាធិការនិងអ្នកត្រួតពិនិត្យឯករាជអន្តរជាតិសម្រាប់ការជ្រើសរើសអត្ថបទស្រាវជ្រាវចុះផ្សាយ។

## ៤.១៧ លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សា

ក. និស្សិតត្រូវសន្សំក្រេឌីតសិក្សាឱ្យបានគ្រប់ចំនួនកំណត់(អប្បបរមា៥៤ក្រេឌីត) ដែលបានបញ្ចប់ដោយជោគជ័យពីគ្រប់ផ្នែកសិក្សានីមួយៗ ដូចមានចែងក្នុងប្រការ២៥ ឬ ប្រការ២៦។

ខ. គ្រឹះស្ថានបណ្តុះបណ្តាលត្រូវ៖

- ផ្តល់ការណែនាំនិងត្រួតពិនិត្យសម្រាប់រាល់ការបញ្ចប់ការសិក្សា ដែលបានមកពីការបញ្ចប់ដោយជោគជ័យ ពីគ្រប់ផ្នែកសិក្សានិងស្រាវជ្រាវនីមួយៗដូចមានកំណត់ក្នុងកម្មវិធីសិក្សា

- ប្រគល់និក្ខេបបទជាឯកសារអេឡិចត្រូនិចដល់មជ្ឈមណ្ឌលគ្រប់គ្រងកម្រងទិន្នន័យស្រាវជ្រាវនៃក្រសួងអប់រំ យុវជន និងកីឡា

- ប្រគល់និក្ខេបបទជាឯកសារបោះពុម្ពមួយច្បាប់សម្រាប់តម្កល់ទុកនៅបណ្ណសារដ្ឋានជាតិកម្ពុជា។

## ៤.១៥ ការផ្លាស់ប្តូរនៅក្នុងពេលដំណើរការបណ្តុះបណ្តាល

**ក. ការប្តូរប្រធានបទ៖**

ការសុំប្តូរប្រធានបទអាចអនុវត្តទៅបាន តែក្នុងពាក់កណ្តាលរយៈពេលបណ្តុះបណ្តាលដើមដំបូង។

**ខ. ការបន្ថែមឬប្តូរសាស្ត្រាចារ្យណែនាំ៖**

អាចប្រព្រឹត្តទៅបានតែក្នុងរយៈពេលយឺតបំផុតមួយឆ្នាំ មុនពេលនិស្សិត ឡើងការពារនិក្ខេបបទបញ្ចប់។

**គ. ការព្យួរការសិក្សា៖**

និស្សិតអាចដាក់ពាក្យសុំទៅនាយកគ្រឹះស្ថានបណ្តុះបណ្តាលសុំព្យួរការសិក្សាបណ្តោះអាសន្ននិងរក្សាទុកលទ្ធផលដែលខ្លួនបានសិក្សា នៅក្នុងករណីដូចខាងក្រោម៖

- ដោយសារជំងឺ ឬឧបទ្ទវហេតុផ្សេងៗ ដោយមានលិខិតបញ្ជាក់ពីមន្ទីរពេទ្យ

- ដោយមូលហេតុផ្ទាល់ខ្លួន ក្នុងករណីនេះនិស្សិតត្រូវសិក្សាបានយ៉ាងតិច១ឆមាស

- និស្សិតដែលព្យួរការសិក្សានៅពេលដែលចង់ត្រឡប់ចូលសិក្សាបន្តវិញត្រូវដាក់ពាក្យសុំមកនាយកគ្រឹះស្ថានបណ្តុះបណ្តាលយ៉ាងតិច១សប្តាហ៍មុនចាប់ផ្តើមឆមាសថ្មី។

**ឃ. ការផ្ទេរការសិក្សា**

និស្សិតអាចអនុញ្ញាតឱ្យផ្ទេរការសិក្សាពីគ្រឹះស្ថានមួយទៅគ្រឹះស្ថានមួយទៀតនៅពេលមានលក្ខខណ្ឌសមស្រប ដូចខាងក្រោម៖

- នៅក្នុងរយៈពេលសិក្សាបើគ្រួសារបានផ្លាស់ប្តូរទីលំនៅ ឬ និស្សិតមានស្ថានភាពលំបាក ចាំបាច់ត្រូវផ្ទេរទៅគ្រឹះស្ថានបណ្តុះបណ្តាលផ្សេងដែលនៅជិតលំនៅដ្ឋានដើម្បីងាយស្រួលក្នុងការសិក្សា

- សុំផ្ទេរទៅគ្រឹះស្ថានបណ្តុះបណ្តាលផ្សេងដែលមានមុខជំនាញបណ្តុះបណ្តាលដូចគ្នា

- ដោយមានការយល់ព្រមពីគ្រឹះស្ថានបណ្តុះបណ្តាលចាស់និងការព្រមទទួលពីគ្រឹះស្ថានបណ្តុះបណ្តាលថ្មី

- បន្ទាប់មកគ្រឹះស្ថានដែលយល់ព្រមទទួលត្រូវធ្វើរបាយការណ៍ជូនក្រសួងទទួលបន្ទុកជ្រាបជាព័ត៌មាន។

និស្សិតមិនអនុញ្ញាតឱ្យផ្ទេរការសិក្សាទៅគ្រឹះស្ថានបណ្តុះបណ្តាលផ្សេងក្នុងករណីដូចខាងក្រោម៖

- កំពុងសិក្សានៅក្នុងឆមាស

- នៅក្នុងដំណាក់កាលកំពុងទទួលវិន័យចាប់ពីការព្រមានឡើងទៅ។

## ជំពូកទី៥
## ការគ្រប់គ្រងការងារបណ្តុះបណ្តាល

### ៥.១ ការគ្រប់គ្រងព័ត៌មានសិក្សា

- ក្រោយពេលបេក្ខបណ្ឌិតបានបំពេញគ្រប់សំណុំបែបបទចុះឈ្មោះចូលរៀនជាផ្លូវការ ការិយាល័យគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតត្រូវបញ្ជូនបញ្ជីឈ្មោះបេក្ខបណ្ឌិតដែលបានជាប់ក្នុងការជ្រើសរើសទៅតាមមហាវិទ្យាល័យ/វិទ្យាស្ថាន ឬ ក្រុមមុខជំនាញ។ បន្ទាប់មក មហាវិទ្យាល័យ/វិទ្យាស្ថាន ឬ ក្រុមមុខជំនាញ រៀបចំដំណើរការការងារផ្ទាល់រវាងបេក្ខបណ្ឌិតជាមួយសាស្ត្រាចារ្យណែនាំគោលដើម្បីកំណត់ប្រធានបទជាផ្លូវការ។
- ក្រោយពីបានការទទួលស្គាល់រយៈពេលមួយខែមក មហាវិទ្យាល័យ/វិទ្យាស្ថាន ឬ ក្រុមមុខជំនាញ បញ្ជូនបញ្ជីឈ្មោះបេក្ខបណ្ឌិត ប្រធានបទស្រាវជ្រាវ និងសាស្ត្រាចារ្យណែនាំគោលទៅការិយាល័យគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិត។ ការិយាល័យគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតរៀបចំបញ្ជីឈ្មោះបេក្ខបណ្ឌិត (សម្រេច) ប្រធានបទស្រាវជ្រាវ សាស្ត្រាចារ្យណែនាំគោល និងរយៈពេលបណ្តុះបណ្តាលរបស់បេក្ខបណ្ឌិតដើម្បីស្នើសុំការឯកភាព និងទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។
- ការិយាល័យគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតត្រូវបញ្ជូនសេចក្តីសម្រេចរបស់ក្រសួងអប់រំ យុវជន និងកីឡា និងបញ្ជីឈ្មោះបេក្ខបណ្ឌិត អាសយដ្ឋានទាក់ទងទៅការិយាល័យរដ្ឋបាលដើម្បីឱ្យផ្តល់ព័ត៌មានទៅបេក្ខជន និងអង្គភាពពាក់ព័ន្ធ។
- គណៈគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាលកម្មវិធីថ្នាក់បណ្ឌិត ចេញសេចក្តីសម្រេចប្រគល់បេក្ខបណ្ឌិតគ្រប់ជំនាញទៅឱ្យមហាវិទ្យាល័យ/វិទ្យាស្ថាន ឬ ក្រុមមុខជំនាញ ដើម្បីរៀបចំកម្មវិធីបណ្តុះបណ្តាលតាមការកំណត់។

គ្រឹះស្ថានបណ្តុះបណ្តាលនីមួយៗត្រូវមានយន្តការផ្តល់ព័ត៌មានជាទៀងទាត់អំពីការគ្រប់គ្រងនិស្សិតថ្នាក់បណ្ឌិតសម្រាប់គ្រឹះស្ថានរបស់ខ្លួន ដែលក្នុងនោះមាន ៖

- បញ្ជីឈ្មោះនិស្សិតប្រចាំឆ្នាំសិក្សាទៅតាមកម្រិតសិក្សា
- ប្រធានបទស្រាវជ្រាវរបស់បេក្ខបណ្ឌិតម្នាក់ៗ ដោយភ្ជាប់ជាមួយក្រុមសាស្ត្រាចារ្យណែនាំ
- កម្រិតជឿនលឿននៃការស្រាវជ្រាវនិក្ខេបបទរបស់បេក្ខបណ្ឌិតម្នាក់ៗ
- ពត៌មានទូទៅអំពីការអនុវត្តកម្មវិធីសិក្សាដែលពាក់ព័ន្ធនឹងមុខវិជ្ជាសិក្សានីមួយៗ និងការងារស្រាវជ្រាវព្រមទាំងកិច្ចការងារដែលត្រូវនិងបានបំពេញដោយបេក្ខបណ្ឌិតក្នុងដំណើរការសិក្សា
- ព័ត៌មានគ្រួសៗអំពីការរៀបចំចាត់ចែងនិងគ្រប់គ្រងរបស់កម្មវិធីសិក្សាថ្នាក់បណ្ឌិត
- ថ្លៃសិក្សា និងរចនាសម្ព័ន្ធថ្លៃសិក្សា(បើមាន)។

### ៥.២ សាស្ត្រាចារ្យបង្រៀនមុខវិជ្ជា

សាស្ត្រាចារ្យបង្រៀនកម្មវិធីបណ្តុះបណ្តាលកម្រិតបណ្ឌិតត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

ក. មានចរិយាសម្បត្តិ និងសីលធម៌ល្អ ជាអ្នកអប់រំគំរូ

ខ. មានសញ្ញាបត្របណ្ឌិត ឬគោរមងារជាសាស្ត្រាចារ្យ សាស្ត្រាចារ្យរង លើមុខជំនាញ ឬវិស័យសមស្របទៅនឹងមុខវិជ្ជាដែលនឹងត្រូវទទួលបន្ទុកបង្រៀននៅក្នុងកម្មវិធីបណ្តុះបណ្តាលកម្រិតបណ្ឌិត។

គ. មានសមត្ថភាពឯកទេសជំនាញលើមុខវិជ្ជាសិក្សាដទៃទៀត ហើយបច្ចុប្បន្នកំពុងធ្វើសកម្មភាពស្រាវជ្រាវ និងធ្លាប់បោះពុម្ពផ្សាយអត្ថបទវិទ្យាសាស្ត្រនិងសៀវភៅសិក្សា និងធ្លាប់បានបង្រៀនកម្មវិធីកម្រិតនេះមួយរយៈកាលកន្លងមក។

## ៥.៣ សាស្ត្រាចារ្យណែនាំគោល

ក. គុណវុឌ្ឍិសាស្ត្រាចារ្យណែនាំគោល

សាស្ត្រាចារ្យណែនាំគោលត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- មានគោរមងារជាសាស្ត្រាចារ្យឬសាស្ត្រាចារ្យរង ដែលមានសញ្ញាបត្របណ្ឌិត។ បើពុំទាន់មានគោរមងារវិទ្យាសាស្ត្រនេះទេ ត្រូវមានអតីតភាពសញ្ញាបត្របណ្ឌិតយ៉ាងតិចត្រឹម៣ឆ្នាំ

- បានឆ្លងកាត់វគ្គបំប៉នគុណវុឌ្ឍិជាសាស្ត្រាចារ្យណែនាំគោល តាមស្តង់ដាដែលបានរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ឬ ស្ថាប័នប្រហាក់ប្រហែល ដើម្បីជាការទទួលស្គាល់អំពីគុណវុឌ្ឍិនៃការណែនាំនិក្ខេបបទ

- មានស្នាដៃនិងកិត្តិនាមក្នុងការចុះផ្សាយអត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រជាតិ និងអន្តរជាតិ

- មានស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការណែនាំវិទ្យាសាស្ត្រ

- អាចប្រើភាសាអង់គ្លេសឬភាសាអន្តរជាតិណាមួយបានល្អក្នុងការស្រាវជ្រាវ និងផ្លាស់ប្តូរវិទ្យាសាស្ត្រជាអន្តរជាតិ

- មានគុណធម៌ និងសីលធម៌ល្អជាអ្នកអប់រំគំរូ។

ការចាត់តាំងសាស្ត្រាចារ្យណែនាំគោល ត្រូវសមស្របទៅនឹងជំនាញសិក្សារបស់និស្សិត ហើយតួនាទីនេះត្រូវស្ថិត នៅរហូតជាមួយរយៈពេលបេក្ខភាពរបស់និស្សិត។ ការរៀបចំចាត់តាំងនេះត្រូវយកចិត្តទុកដាក់គិតគូរដល់ការបង្ការទុកជា មុនក្នុងករណីសាស្ត្រាចារ្យណែនាំគោលអវត្តមានរយៈពេលយូរ ការពុំមានលទ្ធភាព ករណីសុំលាលែងពីតំណែង ឬ ការចូលនិវត្តន៍។ សាស្ត្រាចារ្យណែនាំគោលត្រូវតែជាអ្នកសកម្មក្នុងការងារស្រាវជ្រាវទាក់ទងទៅនឹងមុខជំនាញសិក្សារបស់និស្សិត។

ខ. ភារៈកិច្ច និងការទទួលខុសត្រូវរបស់សាស្ត្រាចារ្យណែនាំគោលមាន ៖

- រៀបចំជំនួបជាទៀងទាត់ និងសិក្ខាសាលាជាមួយបេក្ខបណ្ឌិត
- ណែនាំពីបទដ្ឋាន(ស្តង់ដា) បច្ចេកទេស និងវិធីសាស្ត្រដែលបានតម្រូវ
- គ្រោងរៀបចំ និងយល់ព្រមចំពោះបញ្ជីអំពីចំណុចគោលដៅនិងបញ្ហាសំខាន់ៗមួយចំនួនជាមួយបេក្ខជនបណ្ឌិត ហើយប្រើប្រាស់វាដើម្បីត្រួតពិនិត្យដំណើររីកចម្រើនរបស់បេក្ខជន
- ទាមទារកិច្ចការសំណេរពីបេក្ខជនតាមកាលកំណត់ និងផ្តល់មតិយោបល់រិះគន់ស្ថាបនាត្រឡប់វិញទៅតាមពេលវេលាសមស្រប
- ចាត់ចែងឱ្យបេក្ខជនអនុវត្តការធ្វើបទបង្ហាញផ្ទាល់មាត់អំពីការងារស្រាវជ្រាវរបស់គេនៅក្នុងសិក្ខាសាលា និងសន្និសីទ
- ធានាថាបេក្ខជនត្រូវប្រុងប្រយ័ត្នអំពីកង្វះខាតនៃភាពជឿនលឿន ឬការបរាជ័យក្នុងការឈានទៅដល់កម្រិតស្តង់ដាកិច្ចការដែលអាចទទួលយកបាន
- ចាត់ចែងរកសាស្ត្រាចារ្យណែនាំជំនួស ក្នុងករណីដែលគាត់ពុំមានលទ្ធភាពសម្រាប់រយៈពេលណាមួយ ឬ នៅពេលសាស្ត្រាចារ្យណែនាំលាឈប់ពីគ្រឹះស្ថានបណ្តុះបណ្តាល
- រៀបចំរបាយការណ៍ផ្សេងៗដែលតម្រូវដោយក្រុមប្រឹក្សាវិទ្យាសាស្ត្រ
- ជំរុញឱ្យបេក្ខបណ្ឌិតអាចចុះផ្សាយអត្ថបទក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ ចូលរួមសន្និសីទ ផ្សព្វផ្សាយអត្ថបទ ចូលរួមសមាគមវិជ្ជាជីវៈ។ល។
- ជួយបេក្ខជនក្នុងការរៀបចំឯកសារនិងប្រគល់និក្ខេបបទចុងក្រោយ និង ក្នុងការត្រៀមខ្លួនសម្រាប់ការ ការពារនិក្ខេបបទដោយផ្ទាល់មាត់
- ប្រកាសថានិក្ខេបបទត្រូវបានរួចរាល់សម្រាប់ការការពារបញ្ចប់

- ទទួលខុសត្រូវលើគុណភាពនិក្ខេបបទរបស់និស្សិត។

## ៥.៤ សហសាស្ត្រាចារ្យណែនាំ

សហសាស្ត្រាចារ្យណែនាំគឺជាអ្នកស្រាវជ្រាវជំនាញមានបទពិសោធន៍ខ្ពស់ ស្ថិតនៅក្នុងឬក្រៅស្ថាប័ន ក្នុងឬក្រៅប្រទេស។ សហសាស្ត្រាចារ្យណែនាំមានមុខងារជួយសាស្ត្រាចារ្យណែនាំគោលក្នុងការសម្រេចនូវបេសកកម្មរបស់ខ្លួនដូចជាណែនាំផ្ទាល់និស្សិត សម្រួលឱ្យនិស្សិតបានប្រើប្រាស់ទ្រព្យសម្ភារៈឬទីពិសោធស្រាវជ្រាវដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួន និងជួយផ្តល់ការណែនាំតម្រង់ទិសនិក្ខេបបទជាទូទៅ។

សហសាស្ត្រាចារ្យណែនាំអាចត្រូវបានចាត់តាំងឡើងនៅពេល ត្រូវការឱ្យសមាជិកគណៈកម្មការសាស្ត្រាចារ្យណែនាំណាម្នាក់ដើរតួក្នុងកម្រិតណែនាំនិងគាំទ្រដល់និស្សិតប្រហាក់ប្រហែលទៅនឹងសាស្ត្រាចារ្យណែនាំគោល។ ការសហការណែនាំអាចកើតមាននៅពេលសហសាស្ត្រាចារ្យណែនាំជាសហការីជាមួយសាស្ត្រាចារ្យណែនាំគោល ឬ ជាអ្នកដឹកនាំគម្រោងស្រាវជ្រាវសម្រាប់គាំទ្រដល់ការរៀបចំនិក្ខេបបទនិស្សិត ផ្តល់ការណែនាំសំខាន់នៅក្នុងមុខជំនាញដែលមិនមែនជាឯកទេសជំនាញរបស់សាស្ត្រាចារ្យណែនាំគោល ឬ ជាអ្នកណែនាំនិងគ្រប់គ្រងទីពិសោធឬការដ្ឋានដែលនិស្សិតធ្វើការស្រាវជ្រាវ។

## ៥.៥ សាស្ត្រាចារ្យណែនាំរង

សាស្ត្រាចារ្យណែនាំរងគឺជាសាស្ត្រាចារ្យឬអ្នកជំនាញមានសញ្ញាបត្របណ្ឌិតលើមុខជំនាញសមស្របជាមួយនិងប្រធានបទនិក្ខេបបទស្រាវជ្រាវនិស្សិត មានភារៈកិច្ចជួយដល់និស្សិតក្នុងការកំណត់និងអភិវឌ្ឍកម្មវិធីសិក្សាស្រាវជ្រាវមួយសមស្រប និងធ្វើរបាយការណ៍អំពីភាពជឿនលឿនរបស់និស្សិតជូនដល់គណៈកម្មការគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិត (ប្រការ៦ អនុក្រឹត្យ១៥១ អនក្រ. បក)។

## ៥.៦ គណៈកម្មការសាស្ត្រាចារ្យណែនាំ

បេក្ខបណ្ឌិតម្នាក់ៗត្រូវដឹកនាំដោយគណៈកម្មការសាស្ត្រាចារ្យណែនាំមួយ ដែលមានសមាជិកបី (៣) រូបគឺប្រធានមួយរូបជាសាស្ត្រាចារ្យណែនាំគោល និងសាស្ត្រាចារ្យណែនាំរងឬសហសាស្ត្រាចារ្យណែនាំចំនួនពីរ (២)រូបទៀតជាសមាជិក ដែលជាសាស្ត្រាចារ្យនៅក្នុងឬក្រៅស្ថាប័នបណ្តុះបណ្តាលក្នុងឬក្រៅប្រទេស។

សាស្ត្រាចារ្យណែនាំគោល ត្រូវតែជាសាស្ត្រាចារ្យពេញម៉ោងរបស់គ្រឹះស្ថានបណ្តុះបណ្តាល ហើយអាចដឹកនាំបេក្ខជនបណ្ឌិតសរុបមិនលើសពីប្រាំបួន(៩)រូបក្នុងពេលតែមួយ។

តួនាទីគណៈកម្មការសាស្ត្រាចារ្យណែនាំត្រូវបានបែងចែកដូចខាងក្រោម៖

- សាស្ត្រាចារ្យណែនាំគោលជាអ្នកដើរតួសំខាន់ក្នុងទំនាក់ទំនងជាមួយនិស្សិតនិងទាំងទទួលខុសត្រូវចំពោះការរៀបចំជំនួបជាប្រចាំ និងផ្តល់ការណែនាំលើការងារស្រាវជ្រាវ។ សាស្ត្រាចារ្យណែនាំគោលដើរតួជាប្រធានរបស់គណៈកម្មការសាស្ត្រាចារ្យណែនាំនៅរាល់ការជួបប្រជុំ រួមទាំងការប្រឡងត្រួតពិនិត្យផងដែរ។
- សមាជិកគណៈកម្មការសាស្ត្រាចារ្យណែនាំ គប្បីចូលរួមផ្តល់យោបល់តាមជំនាញឯកទេសរបស់ខ្លួនម្នាក់ៗដល់និស្សិតក្នុងករណីមានការស្នើសុំ។ ពួកគេក៏នឹងត្រូវចូលរួមក្នុងការអានជំពូកផ្សេងៗនៃនិក្ខេបបទទៅតាមការដែលគេបានរៀបចំទុកជាមុននិងក្នុងដំណើរការប្រឡងត្រួតពិនិត្យ។ សមាជិកម្នាក់ៗអាចផ្តល់នូវទស្សនៈឯករាជផ្ទាល់ខ្លួនក្នុងករណីមានទំនាស់រវាងបេក្ខជននិងសាស្ត្រាចារ្យណែនាំគោល។
- ក្រុមនេះត្រូវទទួលខុសត្រូវចំពោះគុណភាពនៃដំណើរការណែនាំនិងជំរុញឱ្យមានការអភិវឌ្ឍផ្នែកបញ្ញារបស់បេក្ខជន។
- សមាជិករបស់គណៈកម្មការណែនាំនេះអាចផ្តល់ការគាំទ្រអំពីការណែនាំក្នុងករណីដែលសាស្ត្រាចារ្យណែនាំគោលអវត្តមាន។

បើសមាជិកណាម្នាក់របស់ក្រុមនេះមិនមានបទពិសោធន៍ក្នុងការណែនាំ គេនឹងអាចមានការយល់ដឹងជ្រៅជ្រះ និងភាពជំនាញក្នុងការណែនាំឆ្លងតាមការងារជាក្រុម។ នៅក្នុងករណីនេះការទទួលខុសត្រូវ របស់ពួកគេអាចកំណត់ត្រឹមៈ

- ចូលរួមរាល់ការជួបប្រជុំជាមួយនិស្សិត
- ផ្តល់មតិកែលម្អលើសេចក្តីព្រាងរបាយការណ៍ អត្ថបទ ឬជំពូកផ្សេងៗរបស់និក្ខេបបទ
- ផ្តល់ឱវាទទៅតាមវិស័យជំនាញឯកទេសរបស់ពួកគេ និង
- ចូលរួមក្នុងដំណើរការប្រឡងត្រួតពិនិត្យ ។

## ៥.៧ គណៈកម្មការការពារគម្រោងពិស្តារ

គណៈកម្មការការពារគម្រោងពិស្តារមានភារៈកិច្ចពិនិត្យនិងផ្តល់យោបល់ទៅលើសំណើគម្រោងស្រាវជ្រាវពិស្តាររបស់និស្សិត មុនពេលអនុញ្ញាតឱ្យចាប់ផ្តើមធ្វើការស្រាវជ្រាវផ្នែកសំខាន់។ យន្តការនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងជួយរួមចំណែកដល់ក្រុមសាស្ត្រាចារ្យណែនាំ ក្នុងការតម្រង់ទិសស្រាវជ្រាវរបស់និស្សិតដើម្បីធ្វើឱ្យប្រាកដឡើងថាលទ្ធផលស្រាវជ្រាវនៅពេលខាងមុខរបស់គេនឹងសង្ឃឹមទទួលយកបាន បើគេប្រតិបត្តិទៅតាមគម្រោងដែលបានឯកភាព។

គណៈកម្មការនេះត្រូវស្នើឡើងដោយមហាវិទ្យាល័យ/វិទ្យាស្ថាន ឬ ក្រុមមុខជំនាញដើម្បីនាយកគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតរៀបចំលិខិតឧទ្ទេសនាម ដែលនៅក្នុងនោះមានសមាសភាពប្រាំ(៥)រូបដឹកនាំដោយសាស្ត្រាចារ្យណែនាំគោល។ ក្រុមសាស្ត្រាណែនាំទាំងអស់ជាសមាជិកនិងសមាសភាពពីរ(២)រូបទៀតសុទ្ធសឹងតែជាបណ្ឌិតដែល មានបទពិសោធន៍ស្រាវជ្រាវក្នុងមុខជំនាញពាក់ព័ន្ធទៅនឹងប្រធានបទនិក្ខេបបទ។ ការរៀបចំឱ្យការពារគម្រោងពិស្តារត្រូវធ្វើឡើងនៅពេលនិស្សិតបានបញ្ចប់ដោយជោគជ័យគ្រប់មុខវិជ្ជាប្រឡង។

## ៥.៨ គណៈកម្មការការពារនិក្ខេបបទសាកល្បង

គោលបំណងនៃការរៀបចំគណៈកម្មការការពារនិក្ខេបបទសាកល្បងគឺជួយដល់គណៈកម្មការសាស្ត្រាចារ្យណែនាំ និងនិស្សិត ក្នុងការជួយវាយតម្លៃនិងផ្តល់យោបល់ទៅលើលក្ខណៈសម្បត្តិនៃនិក្ខេបបទរបស់បេក្ខបណ្ឌិត ថាតើសមស្របសម្រាប់ឱ្យរៀបចំការការពារបញ្ចប់ហើយឬនៅ។ បើនៅខ្វះខាត តើគួរបំពេញនិងកែលម្អលើបញ្ហាអ្វីខ្លះ។ យន្តការនេះ មានសារៈប្រយោជន៍ចាំបាច់ ដើម្បីរួមចំណែកពង្រឹងគុណភាពនិក្ខេបបទនៅពេលដែលក្រុមមុខជំនាញ និងគ្រឹះស្ថានបណ្តុះបណ្តាលពុំទាន់រឹងមាំ។

គណៈកម្មការនេះត្រូវបានរៀបចំឡើងដោយការស្នើសុំរបស់មហាវិទ្យាល័យ/វិទ្យាស្ថាន ឬ ក្រុមមុខជំនាញទៅនាយកគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិត ដើម្បីឱ្យនាយកគ្រឹះស្ថានបណ្តុះបណ្តាលចេញលិខិតឧទ្ទេសនាមបង្កើតគណៈកម្មការការពារនិក្ខេបបទសាកល្បង នៅពេលដែលបេក្ខបណ្ឌិតបានបំពេញជោគជ័យគ្រប់លក្ខខណ្ឌដែលបានតម្រូវរួចហើយ ដូចមានចែងក្នុងប្រការ ៨ ឬ ប្រការ ៩នៃប្រកាសនេះ។

គណៈកម្មការការពារនិក្ខេបបទសាកល្បងមានសមាសភាពប្រាំពីរ(៧)រូប សុទ្ធសឹងជាបណ្ឌិតមានបទពិសោធន៍ស្រាវជ្រាវពាក់ព័ន្ធទៅនឹងប្រធានបទនិក្ខេបបទ ដោយក្នុងនោះត្រូវរៀបចំឱ្យមានសាស្ត្រាចារ្យវាយតម្លៃបី(៣)រូបដែលជាអ្នកមានជំនាញដូចទៅនឹងប្រធានបទនិក្ខេបបទ និងមិនមែនជាសមាជិកក្រុមសាស្ត្រាចារ្យណែនាំ ហើយនៅក្នុងនោះពីរ(២)រូបត្រូវតែជាអ្នកជំនាញមកពីក្រៅគ្រឹះស្ថានបណ្តុះបណ្តាល។ ក្រុមសាស្ត្រាចារ្យណែនាំមួយចំនួនអាចស្ថិតនៅក្នុងគណៈកម្មការនេះផងដែរ ប៉ុន្តែមិនត្រូវជាប្រធានឬលេខាកត់ត្រារបស់គណៈកម្មការនេះទេ។ សមាជិកគណៈកម្មការការពារនិក្ខេបបទសាកល្បងមានភារៈកិច្ចទទួលខុសត្រូវតែនៅក្នុងគណៈកម្មការនេះប៉ុណ្ណោះ។

## ៥.៩ គណៈកម្មការពិនិត្យនិងវាយតម្លៃនិក្ខេបបទឯករាជ

គណៈកម្មការពិនិត្យនិងវាយតម្លៃនិក្ខេបបទឯករាជត្រូវរៀបចំឡើងនៅមុនពេលបង្កើតគណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់។ គណៈកម្មការពិនិត្យនិងវាយតម្លៃនិក្ខេបបទត្រូវបង្កើតឡើងនិងយល់ព្រមដោយគ្រឹះស្ថានបណ្តុះបណ្តាល។

សមាសភាពគណៈកម្មការនេះមានបីរូប មួយរូបជាអ្នកវាយតម្លៃរបស់គ្រឹះស្ថានបណ្តុះបណ្តាល និង ពីររូបទៀតជាអ្នកវាយតម្លៃមកពីខាងក្រៅ។ អ្នកពិនិត្យនិងវាយតម្លៃមិនត្រូវជាប់ញាតិសន្តានជាមួយបេក្ខជន ឬជាអ្នករួមការងារជាមួយគ្នា។ សមាជិកវាយតម្លៃដោយឯករាជនីមួយៗសុទ្ធសឹងតែជាអ្នកវិទ្យាសាស្ត្រនៅក្នុង ឬ ក្រៅប្រទេសដែលមានកម្រិតឯកទេស ជំនាញនិងមូលដ្ឋានវិទ្យាសាស្ត្ររឹងមាំនៅក្នុងវិស័យប្រធានបទស្រាវជ្រាវរបស់បេក្ខបណ្ឌិត និង មានគុណធម៌និងសីល ធម៌ល្អ។ យោបល់របស់សមាជិកគណៈកម្មការវាយតម្លៃឯករាជនីមួយៗ មានតម្លៃជាការប្រឹក្សាឱ្យក្រសួងអប់រំ យុវជន និង កីឡា ក្នុងការពិនិត្យវាយតម្លៃគុណភាពនិក្ខេបបទបណ្ឌិត ហើយនិងការសម្រេចចិត្តឱ្យបេក្ខបណ្ឌិតការពារនិក្ខេបបទ។

បញ្ជីឈ្មោះអ្នកពិនិត្យនិងវាយតម្លៃឯករាជគឺជាឯកសារសម្ងាត់របស់គ្រឹះស្ថានបណ្តុះបណ្តាល និងក្រសួងអប់រំ យុវជន និងកីឡា។ ក្រុមមុខជំនាញ ក្រុមសាស្ត្រាចារ្យណែនាំ និងបេក្ខបណ្ឌិតមិនត្រូវបានឱ្យស្គាល់សមាសភាពគណៈ កម្មការពិនិត្យនិងវាយតម្លៃឯករាជនេះឡើយ។ អ្នកពិនិត្យនិងវាយតម្លៃឯករាជម្នាក់ៗត្រូវទទួលខុសត្រូវ រក្សាការសម្ងាត់អំពីភារកិច្ចរបស់ខ្លួនចាប់តាំងពីពេលទទួលភារកិច្ចនេះរហូតដល់ការចូលរួមក្នុងគណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់។

នៅពេលបានទទួលយោបល់ពីគណៈកម្មការនេះអំពីការគាំទ្រនិក្ខេបបទដោយសំឡេងភាគច្រើនដាច់ខាត ក្រសួងអប់រំ យុវជន និងកីឡានឹងចេញលិខិតឧទ្ទេសនាមបង្កើតគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់ឱ្យបេក្ខបណ្ឌិត។

នៅពេលមានសមាជិកពិនិត្យនិងវាយតម្លៃឯករាជមិនគាំទ្រនិក្ខេបបទដោយសំឡេងភាគច្រើន និក្ខេបបទត្រូវបញ្ជូនត្រឡប់វិញដើម្បីធ្វើការកែលម្អ។ បេក្ខបណ្ឌិតអាចដាក់ស្នើសុំការការពារឡើងវិញយ៉ាងតិចរយៈពេលប្រាំមួយខែ និង យ៉ាងយូរបំផុតរយៈពេលពីរឆ្នាំគិតចាប់ពីថ្ងៃបញ្ជូនត្រឡប់វិញ។ និក្ខេបបទក្រោយពេលកែលម្អរួចត្រូវឆ្លងកាត់គណៈកម្មការពិនិត្យនិងវាយតម្លៃឯករាជលើកមុន ដើម្បីសុំយោបល់ជាថ្មី។

គ្រឹះស្ថានបណ្តុះបណ្តាលត្រូវធ្វើសេចក្តីណែនាំលម្អិតអំពីភារកិច្ចរបស់អ្នកពិនិត្យនិងវាយតម្លៃឯករាជបញ្ជីឈ្មោះ លំដាប់លំដោយ លំនាំជ្រើសរើស ការបញ្ជូននិងការទទួលយោបល់ពីអ្នកពិនិត្យនិងវាយតម្លៃឯករាជ ភាពទទួលខុសត្រូវក្នុងការរក្សាការសម្ងាត់ចំពោះបុគ្គលដែលពាក់ព័ន្ធក្នុងការការពារឯករាជភាពឱ្យអ្នកពិនិត្យនិងវាយតម្លៃឯករាជ។

## ៥.១០ គណៈកម្មការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់

គណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់មានសមាសភាពប្រាំពីរ(៧)រូប សុទ្ធសឹងជាបណ្ឌិតដែលមានគោរមងារវិទ្យាសាស្ត្រ ឬ មានអតីតភាពបណ្ឌិតយ៉ាងតិចបី(៣)ឆ្នាំនិងមានមូលដ្ឋានវិទ្យាសាស្ត្ររឹងមាំក្នុងមុខជំនាញ មានអាកប្បកិរិយា និងសីលធម៌ល្អ និង មានស្នាដៃស្រាវជ្រាវពាក់ព័ន្ធនឹងប្រធានបទនិក្ខេបបទរបស់បណ្ឌិត។

គណៈកម្មការនេះរួមមានប្រធានមួយរូប លេខាកត់ត្រាមួយ(១)រូប គណៈកម្មការពិនិត្យនិងវាយតម្លៃនិក្ខេបបទឯករាជបី(៣)រូប សាស្ត្រាចារ្យណែនាំគោលមួយ(១)រូប និង សមាជិកមួយ(១)រូបទៀតដែលមិនមែនជាសហសាស្ត្រាចារ្យឬសាស្ត្រាចារ្យណែនាំរង ឬ អ្នកដែលមិនមានជាប់សាច់សារលោហិតជាមួយបេក្ខបណ្ឌិត។

ប្រធានគណៈកម្មការនេះត្រូវតែជាអ្នកមានភាពជឿជាក់ក្នុងការស្រាវជ្រាវមុខជំនាញនិងមានសក្តានុពលក្នុងការសម្របសម្រួលនិងដោះស្រាយបញ្ហាក្នុងដំណើរការការពារនិក្ខេបបទរបស់បេក្ខជន។ សមាជិករបស់គណៈកម្មការនេះមានភារៈកិច្ចទទួលខុសត្រូវតែនៅក្នុងគណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់ប៉ុណ្ណោះ។

សមាសភាពគណៈកម្មការនេះត្រូវស្នើឡើងដោយគ្រឹះស្ថានបណ្តុះបណ្តាល និង សម្រេចរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ឬ ថ្នាក់ប្រហាក់ប្រហែល។

## ៥.១១ គណៈកម្មការគ្រប់គ្រងកម្មវិធីថ្នាក់បណ្ឌិតនិងការិយាល័យទទួលបន្ទុក

គ្រឹះស្ថានបណ្តុះបណ្តាលថ្នាក់បណ្ឌិតត្រូវរៀបចំឱ្យមានគណៈកម្មការគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតរបស់ខ្លួន ដើម្បីរៀបចំ គ្រប់គ្រង សម្របសម្រួល ត្រួតពិនិត្យ និង វាយតម្លៃរាល់សកម្មភាពនិងកម្មវិធីបណ្តុះបណ្តាលថ្នាក់

បណ្ឌិតឱ្យបានត្រឹមត្រូវតាមយន្តការដែលបានកំណត់ ដោយគិតចាប់តាំងពីការប្រឡងជ្រើសរើសនិស្សិតឱ្យចូលសិក្សា រហូតដល់ការវាយតម្លៃប្រគល់សញ្ញាបត្រ។

គណៈកម្មការគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិត(ឬមហាវិទ្យាល័យថ្នាក់ក្រោយបរិញ្ញា ចំពោះគ្រឹះស្ថានដែលមាន) ត្រូវមានសេនាធិការផ្ទាល់របស់ខ្លួនមួយឱ្យឈ្មោះថាផ្នែកឬការិយាល័យគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិត ដែលជាលេខាធិការដ្ឋានអចិន្ត្រៃយ៍សម្រាប់គាំទ្រដល់រដ្ឋបាលសិក្សាដោយឡែក។

### ៥.១២ ក្រុមប្រឹក្សាវិទ្យាសាស្ត្រ

គ្រឹះស្ថានបណ្តុះបណ្តាលថ្នាក់បណ្ឌិតត្រូវរៀបចំក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយរបស់គ្រឹះស្ថានផ្ទាល់ ដែលជាស្ថាប័នប្រឹក្សាឱ្យនាយកគ្រឹះស្ថានអំពីវិស័យស្រាវជ្រាវវិទ្យាសាស្ត្រនិងបណ្តុះបណ្តាលធនធានមនុស្សកម្រិតខ្ពស់របស់គ្រឹះស្ថាន។

ក្រុមប្រឹក្សាវិទ្យាសាស្ត្រមានសមាសភាពជាអ្នកវិទ្យាសាស្ត្រ នៅក្នុងឬក្រៅស្ថាប័ន ដែលមានកម្រិតជំនាញខ្ពស់ស៊ីជម្រៅនៅក្នុងវិស័យវិទ្យាសាស្ត្រទាំងឡាយដែលមាននៅក្នុងស្ថាប័ន មានគុណធម៌និងស្មារតីទទួលខុសត្រូវ កំពុងបំពេញការងារក្នុងមុខនាទីច្រើន និងត្រូវបាននាយកគ្រឹះស្ថានអញ្ជើញចូលរួមក្នុងក្រុមប្រឹក្សា។ ក្រុមប្រឹក្សាវិទ្យាសាស្ត្រ មានភារកិច្ចផ្តល់ការប្រឹក្សាដល់នាយកគ្រឹះស្ថានក្នុងការងាររៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្ថាប័ន កំណត់ទិសដៅភារកិច្ច ផែនការរយៈពេលវែង និងអំពីវិស័យអាទិភាពស្រាវជ្រាវវិទ្យាសាស្ត្រ គោលនយោបាយនិងយន្តការក្នុងការគ្រប់គ្រងវិទ្យាសាស្ត្រ អំពីការរៀបចំអនុវត្តកម្មវិធីនិងផែនការបណ្តុះបណ្តាលប្រកបដោយគុណភាព ការធ្វើក្រឹតការអ្នកវិទ្យាសាស្ត្ររៀបចំការវាយតម្លៃស្នាដៃវិទ្យាសាស្ត្រតាមសំណើនាយកគ្រឹះស្ថាន ហើយនិងពិនិត្យជ្រើសរើសស្នាដៃស្រាវជ្រាវដែលមានគុណភាពនិងអ្នកវិទ្យាសាស្ត្រដែលមានស្នាដៃក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រ សម្រាប់ការលើកសរសើររបស់ថ្នាក់លើ។

ក្រុមប្រឹក្សាវិទ្យាសាស្ត្រត្រូវទទួលខុសត្រូវជួយនាយកគ្រឹះស្ថានបណ្តុះបណ្តាលក្នុងការធានាការអនុវត្តបទដ្ឋានសិក្សានិងការធ្វើផែនការកម្ម ការសម្របសម្រួល ការអភិវឌ្ឍ និង ការត្រួតពិនិត្យកិច្ចការអប់រំទាំងនោះ ហើយនិងក្នុងការរក្សានិងអភិវឌ្ឍស្តង់ដាសិក្សារបស់កម្មវិធី និង សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រនានារបស់គ្រឹះស្ថានបណ្តុះបណ្តាល។

### ៥.១៣ ភារទទួលខុសត្រូវរបស់បេក្ខបណ្ឌិត

ដើម្បីធានាបាននូវភាពជឿនលឿនគ្រប់គ្រាន់ និស្សិតត្រូវ ៖

- បញ្ចប់ដោយជោគជ័យគ្រប់មុខវិជ្ជាសិក្សា ការអានឯកសារ ការប្រឡងត្រួតពិនិត្យ និងការប្រគល់ជូនឯកសារផ្សេងៗតាមតម្រូវការរបស់គ្រឹះស្ថានបណ្តុះបណ្តាល
- ផ្តល់គ្រប់ព័ត៌មានចាំបាច់ដល់ផ្នែករដ្ឋបាលនៃគ្រឹះស្ថានបណ្តុះបណ្តាលត្រូវការ
- ព្រមព្រៀងអំពីផែនការសកម្មភាពជាមួយក្រុមសាស្ត្រាចារ្យណែនាំ។ ផែនការសកម្មភាពនោះ គប្បីរួមមាន ៖
    - ការត្រួតពិនិត្យឡើងវិញប្រចាំឆ្នាំ និងអត្ថបទស្រាវជ្រាវ
    - របាយការណ៍អំពីភាពជឿនលឿននៅតាមឆមាសនីមួយៗ
- ផ្តល់បទបង្ហាញជាផ្លូវការតាមរយៈសិក្ខាសាលាប្រចាំឆ្នាំ
- រៀបចំការចុះផ្សាយអត្ថបទស្រាវជ្រាវយ៉ាងតិចឱ្យបានតាមចំនួនកំណត់មុនពេលការឡើងការពារបញ្ចប់
- ធានាថាភាពជឿនលឿននៃកិច្ចការរបស់ពួកគេ ដើរស្របទៅនឹងផែនការសកម្មភាពដែលបានកំណត់ទុក។ រាល់ការប្រែប្រួលចំពោះផែនការនោះត្រូវមានការឯកភាពយល់ព្រមពីសាស្ត្រាចារ្យណែនាំគោល
- រៀបចំចាត់ចែងសម្រាប់ការជួបប្រជុំជាប្រចាំជាមួយសាស្ត្រាចារ្យណែនាំ
- លើកបញ្ហា ឬ ឧបសគ្គផ្សេងៗ យកមកពិភាក្សាជាមួយសាស្ត្រាចារ្យណែនាំ
- កត់ត្រា និងឆ្លើយតបទៅនឹងមតិរិះគន់ផ្សេងៗដែលធ្វើឡើងដោយសាស្ត្រាចារ្យណែនាំចំពោះកិច្ចការស្រាវជ្រាវដែលបានដាក់ជូនពិនិត្យ

- និស្សិតដែលគិតថាកិច្ចការរបស់គេមិនមានភាពជឿនលឿនគ្រប់គ្រាន់ដោយសារមូលហេតុមួយចំនួនដែលហួសពីសមត្ថភាពដោះស្រាយរបស់គេ ត្រូវលើកយកមកពិភាក្សាជាមួយសាស្ត្រាចារ្យណែនាំ
- រៀបចំ និងដាក់ជូននិក្ខេបបទចុងក្រោយរបស់គេសម្រាប់ការពិនិត្យនិងវាយតម្លៃ ហើយនិងការការពារបញ្ចប់
- គោរពតាមក្រមសីលធម៌ស្រាវជ្រាវ។

ការលួចចម្លងស្នាដៃ គឺមានរាប់បញ្ចូលទាំងការប្រើប្រាស់កិច្ចការច្នៃប្រឌិតរបស់អ្នកដទៃដោយថាជារបស់ខ្លួនផ្ទាល់ទៅវិញ ការដកស្រង់អត្ថបទ ទិន្នន័យ រូប រូបភាព តារាង។ល។ ឬ ការប្រើប្រាស់គំនិតដើមរបស់អ្នកដទៃមកពីប្រភពខាងក្រៅដោយបំភ្លេចមិនបានប្រាប់ពីប្រភពដើមរបស់វា។ អំពើនេះត្រូវបានចាត់ទុកថាជាកំហុសមួយដ៏ធ្ងន់ធ្ងរសម្រាប់អ្នកស្រាវជ្រាវ ហើយអាចឈានទៅដល់ការបញ្ឈប់បេក្ខភាពភ្លាមៗ ឬ ដកហូតសញ្ញាបត្រក្នុងករណីរកឃើញនៅពេលក្រោយ។

## ៥.១៤ ការទទួលខុសត្រូវរបស់ក្រុមមុខជំនាញ

រៀបចំអនុគណៈកម្មការតាមមុខជំនាញដើម្បីពិនិត្យជ្រើសរើសនិស្សិតឱ្យចូលរៀនថ្នាក់បណ្ឌិត ដោយធ្វើការវាយតម្លៃទៅលើសំណុំលិខិត សមត្ថភាព ស្នាដៃ និងសីលធម៌របស់បេក្ខជនម្នាក់ៗ។ រៀបចំបំពេញសាលាកបត្រវាយតម្លៃ ចាត់ថ្នាក់លទ្ធផលប្រឡងជ្រើសរើសនិស្សិតថ្នាក់បណ្ឌិត រួចហើយបញ្ជូនទៅឱ្យគណៈកម្មការប្រឡងជ្រើសរើសពិនិត្យនិងសម្រេច។

ពិនិត្យ និងបញ្ជូនតាមរយៈក្រុមប្រឹក្សាវិទ្យាសាស្ត្រ ឬ មហាវិទ្យាល័យ/វិទ្យាស្ថានរបស់គ្រឹះស្ថានបណ្តុះបណ្តាលមុននឹងប្រគល់ឱ្យនាយកគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតសម្រេចអំពីមុខវិជ្ជាសិក្សាចាំបាច់ក្នុងកម្មវិធីបណ្តុះបណ្តាលកម្រិតបណ្ឌិតដែលរួមមាន៖ មុខវិជ្ជាសិក្សាបំពេញបន្ថែម មុខវិជ្ជាជំនាញកម្រិតបណ្ឌិត ផែនការបណ្តុះបណ្តាលសម្រាប់បេក្ខបណ្ឌិតម្នាក់ៗ តាមដាននិងត្រួតពិនិត្យការអនុវត្តកម្មវិធីនិងផែនការបណ្តុះបណ្តាលបេក្ខបណ្ឌិតនោះ។

រៀបចំការប្រជុំជីវភាពវិទ្យាសាស្ត្រជំនាញតាមកាលកំណត់សម្រាប់សាស្ត្រាចារ្យនិងបេក្ខបណ្ឌិត យ៉ាងតិចមួយខែម្តង ដើម្បីឱ្យបេក្ខបណ្ឌិតឡើងបង្ហាញអំពីជំនាញតម្រង់ទិសនិងលទ្ធផលស្រាវជ្រាវ បែងចែកការងារឱ្យបេក្ខជនបណ្ឌិតហ្វឹកហាត់ និងជួយណែនាំការស្រាវជ្រាវបន្ត។

សម្រេចកាលវិភាគការងាររបស់បេក្ខបណ្ឌិតនិងសាស្ត្រាចារ្យណែនាំ កាលវិភាគរបស់ក្រុមមុខជំនាញស្តាប់បេក្ខបណ្ឌិតឡើងបង្ហាញលទ្ធផលសិក្សានិងស្រាវជ្រាវក្នុងឆ្នាំសិក្សាឱ្យបានយ៉ាងតិចបួន(៤)ដងក្នុងមួយឆ្នាំ។ រៀបចំពិនិត្យវាយតម្លៃលទ្ធផលសិក្សានិងស្រាវជ្រាវ ស្មារតីនិងអាកប្បកិរិយាក្នុងការសិក្សានិងការស្រាវជ្រាវ លទ្ធភាពនិងសេចក្តីសង្ឃឹមរបស់បេក្ខបណ្ឌិត ហើយនិងស្នើឡើងទៅនាយកគ្រប់គ្រងកម្មវិធីថ្នាក់បណ្ឌិតក្នុងការសម្រេចឱ្យបន្តការសិក្សាចំពោះបេក្ខបណ្ឌិតម្នាក់ៗ។

រៀបចំជូននាយកគ្រប់គ្រងថ្នាក់បណ្ឌិតនូវបញ្ជីឈ្មោះទស្សនាវដ្តីវិទ្យាសាស្ត្រជំនាញដែលមានក្រុមត្រួតពិនិត្យឯករាជដែលបេក្ខបណ្ឌិតត្រូវផ្ញើចុះផ្សាយលទ្ធផលស្រាវជ្រាវរបស់ខ្លួន សមស្របតាមប្រការ៣៨នៃប្រកាសនេះ។ ណែនាំទំនាក់ទំនង និងជួយបេក្ខបណ្ឌិតក្នុងការផ្ញើអត្ថបទចុះផ្សាយលទ្ធផលស្រាវជ្រាវនៅក្នុងនិងក្រៅប្រទេស។

ស្នើទៅនាយកគ្រប់គ្រងថ្នាក់បណ្ឌិតអំពីការផ្លាស់ប្តូរប្រធានបទនិក្ខេបបទ បំពេញឬផ្លាស់ប្តូរសាស្ត្រាចារ្យណែនាំ កាត់បន្ថយឬពន្យារពេលបណ្តុះបណ្តាល និងផ្លាស់ប្តូរគ្រឹះស្ថានបណ្តុះបណ្តាលរបស់និស្សិត។

មាននិវិធានការនិងអនុវត្តការគ្រប់គ្រងម៉ឺងម៉ាត់ចំពោះបេក្ខបណ្ឌិតក្នុងដំណើរការសិក្សានិងស្រាវជ្រាវ។ រាយការណ៍ទៀងទាត់ប្រាំមួយ(៦)ខែម្តងអំពីស្ថានភាពសិក្សានិងស្រាវជ្រាវរបស់បេក្ខបណ្ឌិត។

រៀបចំវាយតម្លៃនិក្ខេបបទបេក្ខបណ្ឌិតនៅកម្រិតការពារសាកល្បង បន្ទាប់មកពិនិត្យបញ្ជូន ឬ ផ្អាកការស្នើសុំឱ្យបេក្ខបណ្ឌិតបន្តទៅការការពារបញ្ចប់។

## ៥.១៥ ការទទួលខុសត្រូវរបស់គ្រឹះស្ថានបណ្តុះបណ្តាល

ការទទួលខុសត្រូវរបស់គ្រឹះស្ថានបណ្តុះបណ្តាល គឺត្រូវផ្តល់ ៖

- បរិស្ថានសង្គមនិងបរិស្ថានបញ្ញាសមស្របសម្រាប់ការស្រាវជ្រាវរបស់និស្សិតថ្នាក់បណ្ឌិត
- ឱកាសក្នុងការអភិវឌ្ឍការត្រិះរិះបែបរិះគន់និងវិភាគ
- មុខវិជ្ជាសិក្សាឱ្យសមស្របទៅនឹងកម្រិតនិងធានាបាននូវវិធីសាស្ត្រណែនាំត្រឹមត្រូវ
- មូលដ្ឋានសម្ភារៈគ្រប់គ្រាន់ រួមមានធនធានបណ្ណាល័យ ធនធានបច្ចេកវិទ្យាព័ត៌មាន កម្មវិធីចាំបាច់ និងបន្ទប់សិក្សាដោយឡែក
- ការណែនាំនិងការគាំទ្រការសិក្សា
- រដ្ឋបាលមានស័ក្តិសិទ្ធិភាព
- ការគិតគូរដោយយុត្តិធម៌
- បទបញ្ញត្តិដែលអាចទទួលយកបាន
- គុណវុឌ្ឍិដែលមានចរិតជាតិនិងអន្តរជាតិ។

# ជំពូកទី៦
# ការរៀបចំនិក្ខេបបទ និង ការការពារនិក្ខេបបទ

## ៦.១ ការរៀបចំគម្រោងស្រាវជ្រាវពិស្តារ

និស្សិតត្រូវរៀបចំគម្រោងស្រាវជ្រាវពិស្តារមួយដែលរួមមានផ្នែកសំខាន់ៗ ដូចតទៅ ៖

- សេចក្តីថ្លែងអំពីប្រវត្តិការសិក្សាស្រាវជ្រាវ ការសិក្សាស្រាវជ្រាវមុនៗ និង ចំណោទបញ្ហា
- គោលបំណងនិងវត្ថុបំណងនៃការស្រាវជ្រាវ សំណួរឬសម្មតិកម្មស្រាវជ្រាវ
- សារៈសំខាន់នៃការស្រាវជ្រាវ
- ការប្រើប្រាស់ទ្រឹស្តី/ បញ្ញត្តិ
- ការសំយោគឯកសារស្រាវជ្រាវមុនៗដែលទាក់ទងនឹងប្រធានបទ
- តើការស្រាវជ្រាវនោះនឹងដំណើរការយ៉ាងដូចម្តេច (សម្ភារ និងវិធីសាស្ត្រប្រមូល និងវិភាគទិន្នន័យ)
- ការលើកឡើងពីការគិតគូរដល់ក្រមសីលធម៌ស្រាវជ្រាវក្នុងការប្រមូលទិន្នន័យនិងសរសេរនិក្ខេបបទ
- កំណត់ពេលវេលា និង កិច្ចការដែលត្រូវបំពេញ
- បញ្ជីឯកសារយោង

គម្រោងស្រាវជ្រាវនេះគប្បីត្រូវគាំទ្រដោយអំណះអំណាងឯកសារថ្មីៗ ហើយគប្បីត្រូវត្រួតពិនិត្យនិងឯកភាពដោយគណៈកម្មការសាស្ត្រាចារ្យណែនាំ។ ប្រវែងខ្លឹមសារប្រហាក់ប្រហែល ៣០ទំព័រ។

## ៦.២ ការការពារគម្រោងស្រាវជ្រាវពិស្តារ

និស្សិតត្រូវឡើងការពារគម្រោងស្រាវជ្រាវពិស្តារជាផ្លូវការ និង ជាសាធារណៈនៅចំពោះមុខគណៈកម្មការមួយដែលរៀបចំឡើងដោយមហាវិទ្យាល័យ/វិទ្យាស្ថាន ឬ ក្រុមមុខជំនាញរបស់គ្រឹះស្ថានបណ្តុះបណ្តាល។ គណៈកម្មការនេះនឹងផ្តល់យោបល់កែលម្អលើសំណើស្រាវជ្រាវនោះ និងបន្ទាប់មក តាមរយៈការសាកសួរសំណួរផ្ទាល់មាត់ ដើម្បីឱ្យដឹងថាបេក្ខជនបានត្រៀមលក្ខណៈគ្រប់គ្រាន់ក្នុងការស្រាវជ្រាវហើយឬនៅ។ គណៈកម្មការនេះអាចអនុញ្ញាតឱ្យនិស្សិតដែលបានឆ្លងកាត់ការការពារសំណើដោយជោគជ័យ បន្តចូលដំណាក់កាលបន្ទាប់ដែលជាការចាប់ផ្តើមផ្នែកស្រាវជ្រាវសំខាន់។ ក្នុងករណីដែលតម្រូវឱ្យមានការកែលម្អច្រើន និស្សិតត្រូវដាក់សំណើគម្រោងស្រាវជ្រាវជាថ្មីម្តងទៀតបន្ទាប់ពីបានបំពេញបន្ថែម

ខ្លឹមសារទាំងនេះចប់សព្វគ្រប់ ដើម្បីសុំការយល់ព្រមពីប្រធានគណៈកម្មការការពារគម្រោងពិស្តារថាចាំបាច់ត្រូវសុំការការពារម្តងទៀត ឬ បន្តទៅដំណាក់ការបន្ទាប់តែម្តង។ បើចាំបាច់និស្សិតនិងគណៈកម្មការសាស្ត្រាចារ្យណែនាំអាចសុំការការពារឡើងវិញ បានតែម្តងទៀតប៉ុណ្ណោះនៅចំពោះមុខគណៈកម្មការដដែល។

## ៦.៣ ការរៀបចំនិក្ខេបបទបណ្ឌិត

• និក្ខេបបទថ្នាក់បណ្ឌិតគឺជាស្នាដៃស្រាវជ្រាវថ្មីមួយដែលមានលក្ខណៈវិទ្យាសាស្ត្រ និងមិនទាន់មានអ្នកណាម្នាក់រកឃើញ(ឬទាន់សម័យ) មានការបង្កើតថ្មីនៅក្នុងផ្នែកវិទ្យាសាស្ត្រមានការបំពេញបន្ថែមអំពី ផ្នែកទ្រឹស្តី បង្ហាញពីលក្ខណៈរស់រវើក ឬការបកស្រាយថ្មីដែលមានតម្លៃនៅក្នុងការអភិវឌ្ឍ លើកកម្ពស់ចំណេះដឹងវិទ្យាសាស្ត្ររបស់ផ្នែកស្រាវជ្រាវ ឬដោះស្រាយនូវបញ្ហាថ្មីដែលបានដាក់ចេញជាមួយនឹងជំនាញ វិទ្យាសាស្ត្រ ឬ ការអនុវត្តនៅក្នុងសង្គម។

• និក្ខេបបទថ្នាក់បណ្ឌិតអាចមានចំនួនពី ១០០ ទៅ ៣០០ទំព័រនៃក្រដាស់ទំហំ A4 ក្នុងនោះមាន ៥០% គឺជាការបកស្រាយពីលទ្ធផលនៃការស្រាវជ្រាវ និងការវិភាគរបស់បេក្ខជន (៥០% គឺជាស្នាដៃថ្មីដែលរកឃើញដោយបេក្ខជន)។ បេក្ខជនត្រូវមានអំណះអំណាងត្រឹមត្រូវ និងមានការទទួលខុសត្រូវខ្ពស់លើស្នាដៃស្រាវជ្រាវរបស់ខ្លួន។

• ខ្លឹមសារនិក្ខេបបទត្រូវមានយ៉ាងតិច ៥ផ្នែកៈ ទី១ សេចក្តីផ្តើម ទី២ រំលឹកទ្រឹស្តីនិងការសំយោគឯកសារពាក់ព័ន្ធ ទី៣ វិធីសាស្ត្រស្រាវជ្រាវ ទី៤ លទ្ធផលនិងការពិភាក្សា និងទី៥ សន្និដ្ឋាននិងអនុសាសន៍ (ឬសំណូមពរសិក្សាស្រាវជ្រាវបន្ត)។ ខ្លឹមសារនិក្ខេបបទមិនអនុញ្ញាតឱ្យរាប់បញ្ចូលនូវអារម្ភកថា សេចក្តីថ្លែងអំណរគុណ អំណះអំណាង មាតិកា ពាក្យអក្សរកាត់ ឯកសារយោង និងឧបសម្ព័ន្ធឡើយ។

• និក្ខេបបទថ្នាក់បណ្ឌិតត្រូវធានាឱ្យបាននូវការប្រកាន់យកពីការកំណត់នូវរាល់ការការពារកម្មសិទ្ធិបញ្ញាដែលបានកំណត់នូវក្នុងច្បាប់កម្មសិទ្ធិបញ្ញា។

• បើសិនជាខ្លឹមសារនិក្ខេបបទទាំងមូលជាស្នាដៃវិទ្យាសាស្ត្រ ឬមួយផ្នែកណាជាស្នាដៃវិទ្យាសាស្ត្រដែលបានស្រាវជ្រាវរួមគ្នា(ឬរបស់អង្គភាព) ក្នុងនោះបេក្ខជនដែលជាអ្នករួមចំណែកដែរនោះ គឺត្រូវបង្ហាញ ឬបំភ្លឺទៅក្រសួងអប់រំ យុវជន និងកីឡា និងក្រុមអ្នកនិពន្ធរួមគ្នាគ្រប់រូប ដើម្បីសុំការអនុញ្ញាតឱ្យបេក្ខជនប្រើប្រាស់ស្នាដៃនេះនៅក្នុងនិក្ខេបបទ ក្នុងការការពារយកសញ្ញាបត្របណ្ឌិត។

• ការប្រើប្រាស់ ឬស្រង់យកលទ្ធផលស្រាវជ្រាវរបស់អ្នកដទៃមកបង្ហាញ របស់អ្នកនិពន្ធរួមគ្នាត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់និងគ្រប់គ្រាន់អំពីប្រភព។ បើសិនជាប្រើប្រាស់ទិន្នន័យ(តួលេខ) របស់អ្នកដទៃ (ការបង្ហាញតារាងរូបភាព រូបមន្ត ក្រាហ្វិច ក៏ដូចជាទិន្នន័យផ្សេងៗ) ដែលមិនមានការអនុញ្ញាតពីម្ចាស់ដើមឬប្រាប់អំពីប្រភពច្បាស់លាស់ និក្ខេបបទនោះគឺមិនអនុញ្ញាតឱ្យការពារឡើយ ឬបដិសេធការទទួលស្គាល់វិញបើរកឃើញនៅពេលក្រោយការការពារបញ្ចប់។

• បញ្ជីឯកសារយោងដែលបេក្ខជនបានយកមកប្រើប្រាស់ ដើម្បីសរសេរនិក្ខេបបទ ត្រូវរៀបចំទៅតាមលំដាប់អក្សរដូចជាឈ្មោះអ្នកនិពន្ធ ចំណងជើងអត្ថបទ ទីកន្លែងនិងស្ថាប័នបោះពុម្ពផ្សាយ ឆ្នាំបោះពុម្ព និងលេខទំព័រ។

. ខ្លឹមសារសំខាន់ និងលទ្ធផលស្រាវជ្រាវចម្បងក្នុងនិក្ខេបបទ ត្រូវខិតខំចុះផ្សាយក្នុងកម្រងអត្ថបទសន្និសីទវិទ្យាសាស្ត្រថ្នាក់ជាតិជារៀងរាល់ឆ្នាំនៅតាមជំនាញវិទ្យាសាស្ត្ររបស់ខ្លួន(បើមាន) ឬចុះផ្សាយយ៉ាងតិចបំផុតឱ្យបានចំនួនពីរ អត្ថបទនៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រជំនាញកម្រិតជាតិ ដែលមានក្រុមត្រួតពិនិត្យឯករាជ។

## ៦.៤ ការការពារនិក្ខេបបទសាកល្បង

ក. ក្រោយពេលបេក្ខបណ្ឌិតបានបញ្ចប់ដោយជោគជ័យនូវរាល់កម្មវិធីបណ្តុះបណ្តាលតាមការកំណត់ គណៈកម្មការសាស្ត្រាចារ្យណែនាំណែនាំបេក្ខបណ្ឌិតឱ្យរៀបចំនូវសំណុំបែបបទចាំបាច់ដើម្បីបញ្ជូនទៅមហាវិទ្យាល័យ/វិទ្យាស្ថាន ឬ ក្រុមមុខជំនាញ សម្រាប់សុំការការពារសាកល្បង។

ខ. មហាវិទ្យាល័យ/វិទ្យាស្ថាន ឬ ក្រុមមុខជំនាញប្រគល់សំណុំបែបបទសុំការពារនិក្ខេបបទសាកល្បងរបស់បេក្ខជនបណ្ឌិតជូនទៅនាយកគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិត។ សំណុំបែបបទនោះមាន៖

- លិខិតសុំអនុញ្ញាតការពារនិក្ខេបបទសាកល្បងរបស់បេក្ខបណ្ឌិត ដែលមានការយល់ព្រមពីសាស្ត្រាចារ្យណែនាំគោល

- លិខិតបញ្ជាក់ពីគណៈកម្មការសាស្ត្រាចារ្យណែនាំ ដែលធានាអះអាងទៅលើគុណភាពនិក្ខេបបទ និងការពិនិត្យវាយតម្លៃទៅលើស្មារតី អាកប្បកិរិយា លទ្ធផលសិក្សានិងស្រាវជ្រាវរបស់បេក្ខបណ្ឌិត ហើយសំណូមពរឱ្យបេក្ខបណ្ឌិតបានការពារនិក្ខេបបទសាកល្បង

- លិខិតស្នើសុំរបស់មហាវិទ្យាល័យ/វិទ្យាស្ថាន ឬ ក្រុមមុខជំនាញទៅនាយកគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតដើម្បីឱ្យបេក្ខបណ្ឌិតបានឡើងការពារសាកល្បង (បើសិនជានិស្សិតផុតកំណត់រយៈពេលសិក្សា ត្រូវភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាតឱ្យនិស្សិតពន្យារការសិក្សារបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃគ្រឹះស្ថានបណ្តុះបណ្តាល)

- ពង្រាងបញ្ជីឈ្មោះសមាសភាពគណៈកម្មការការពារនិក្ខេបបទសាកល្បង ដែលមានប្រាំពីរ(៧)រូបរបស់មហាវិទ្យាល័យ/វិទ្យាស្ថាន ឬ ក្រុមមុខជំនាញ

- លិខិតបញ្ជាក់ពីផ្នែក ឬ ការិយាល័យទទួលបន្ទុកកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតថាបេក្ខជនបានបំពេញលក្ខខណ្ឌដោយជោគជ័យនិងគ្រប់សព្វតាមកម្មវិធីបណ្តុះបណ្តាលដូចមានចែងក្នុងប្រការ៨ ឬ ៩នៃប្រកាសនេះ (លើកលែងតែនិក្ខេបបទ)

- លិខិតបញ្ជាក់និងឯកភាពឱ្យបេក្ខបណ្ឌិតប្រើប្រាស់នូវរាល់លទ្ធផលនៃសមិទ្ធិផលវិទ្យាសាស្ត្រ ឬចំណែកដ៏តូចណាមួយនៃសមិទ្ធិផលវិទ្យាសាស្ត្ររួមគ្នា ហើយដែលក្នុងនោះបេក្ខបណ្ឌិតបានយកមកប្រើប្រាស់នៅក្នុងផ្នែកសំខាន់នៃនិក្ខេបបទ(បើចាំបាច់)

- ប្រវត្តិរូបសង្ខេបរបស់បេក្ខជន

- តារាងព្រឹត្តិបត្រពិន្ទុមុខវិជ្ជានានារបស់និស្សិត

គ. ផ្អែកតាមសំណើរបស់មហាវិទ្យាល័យ/វិទ្យាស្ថាន ឬក្រុមមុខជំនាញអំពីសមាសភាពគណៈកម្មការការពារសាកល្បងនិងយោបល់នាយកគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិត នាយកគ្រឹះស្ថានបណ្តុះបណ្តាលចេញសេចក្តីសម្រេចបង្កើតគណៈកម្មការការពារនិក្ខេបបទសាកល្បង

ឃ. លំដាប់លំដោយនៃការការពារនិក្ខេបបទសាកល្បងមាន៖

- តំណាងមហាវិទ្យាល័យ/វិទ្យាស្ថាន ឬ ក្រុមមុខជំនាញឡើងបើកកម្មវិធីអានលិខិតឧទ្ទេសនាមបង្កើតគណៈកម្មការវាយតម្លៃនិក្ខេបបទសាកល្បង ដែលរៀបចំដោយគ្រឹះស្ថានបណ្តុះបណ្តាល និងប្រគល់កម្មវិធីជូនប្រធានគណៈកម្មការការពារសាកល្បង។

- ប្រធានគណៈកម្មការ អានសមាសភាពគណៈកម្មការ និងរបៀបវារៈនៃការការពារនិក្ខេបបទសាកល្បង

- លេខាកត់ត្រា អានប្រវត្តិរូបសង្ខេបរបស់បេក្ខជន និងបណ្តាលក្ខខណ្ឌចាំបាច់មួយចំនួនទៀតដែលធ្វើឱ្យបេក្ខជនបណ្ឌិតបានឡើងការពារសាកល្បង

- បេក្ខបណ្ឌិត ឡើងបង្ហាញនិងបកស្រាយខ្លឹមសារនិក្ខេបបទដោយសង្ខេប

- សមាជិកគណៈកម្មការនីមួយៗផ្តល់យោបល់វាយតម្លៃនិងអនុសាសន៍

- រាល់សមាជិកគណៈកម្មការវាយតម្លៃ និងអ្នកចូលរួមចោទជាសំណួរ ឬផ្តល់យោបល់ទៅលើលទ្ធផលដែលសម្រេចបានរាល់ចំណុចថ្មីរបស់និក្ខេបបទរាល់បញ្ហា ដែលមិនអាចដោះស្រាយបាន និងនូវរាល់ចំណុចដែលត្រូវបំពេញបន្ថែម ឬចំណុចដែលត្រូវកែលម្អ។

- បេក្ខបណ្ឌិតបកស្រាយបំភ្លឺ និងថ្លែងអំណរគុណចំពោះអនុសាសន៍ជាវិជ្ជមានទាំងឡាយ។

- ប្រសិនបើមិនមានបញ្ហាដែលកែតម្រូវ ឬការជំទាស់ទេ គណៈកម្មការចូលប្រជុំដោយឡែក។ សមាជិកម្នាក់ៗរបស់គណៈកម្មការវាយតម្លៃសរសេរយោបល់ផ្ទាល់ខ្លួនចូលទៅក្នុងលិខិតវាយតម្លៃ។ គណៈកម្មការពិភាក្សាយកយោបល់រួមដើម្បីសម្រេចលទ្ធផលសំយោគរបស់ខ្លួន។

* ប្រធានគណៈកម្មការប្រកាសយោបល់រួមរបស់គណៈកម្មការវាយតម្លៃ

* បញ្ចប់កម្មវិធីវាយតម្លៃនិក្ខេបបទសាកល្បង។

ង. យឺតបំផុតចំនួន មួយសប្តាហ៍ចាប់ពីថ្ងៃដែលគណៈកម្មការវាយតម្លៃសាកល្បង ប្រជុំវាយតម្លៃនិក្ខេបបទ មហាវិទ្យាល័យ/វិទ្យាស្ថាន ឬក្រុមមុខជំនាញ រៀបចំឱ្យបានចប់សព្វគ្រប់នូវរាល់សំណុំលិខិតការពារតាមការកំណត់ជូននាយកគ្រប់គ្រងកម្មវិធីថ្នាក់បណ្ឌិត។

## ៦.៥ ការវាយតម្លៃការការពារសាកល្បង

និក្ខេបបទត្រូវបានផ្ញើទៅគណៈកម្មការវាយតម្លៃគ្រប់រូប ឱ្យបានមុនថ្ងៃការពារសាកល្បងយ៉ាងតិចបំផុតឱ្យបាន១៥ថ្ងៃ។ គណៈកម្មការគ្រប់រូបត្រូវអាននិក្ខេបបទនិងសរសេរលិខិតពិនិត្យនិងវាយតម្លៃឱ្យបានមុនការប្រជុំរបស់គណៈកម្មការវាយតម្លៃនិក្ខេបបទសាកល្បង។

ការវាយតម្លៃនិក្ខេបបទសាកល្បងមានកម្រិតដូចខាងក្រោម៖

- សមាជិកគណៈកម្មការវាយតម្លៃនិក្ខេបបទសាកល្បងគ្រប់រូប ត្រូវបញ្ចេញយោបល់វាយតម្លៃអំពីលទ្ធផលថ្មី ចំណុចអន់ថយនិងចំណុចខ្វះខាតរបស់និក្ខេបបទ និងសំណូមពរឱ្យបេក្ខជនធ្វើការកែលម្អនិងបំពេញបន្ថែម។

- និក្ខេបបទអាចអនុញ្ញាតឱ្យបន្តសុំការការពារបញ្ចប់ដែលមិនបាច់មានការកែលម្អ ឬកែលម្អតិចតួចដោយមានការយល់ព្រមពីសមាជិកគណៈកម្មការការពារសាកល្បងគាំទ្រចាប់ពីប្រាំ(៥)នាក់ឡើងទៅ។ បើសមាជិកគណៈកម្មការណាម្នាក់អវត្តមាន ត្រូវផ្ញើលិខិតវាយតម្លៃបញ្ជូនមកឱ្យបានមុនពេលការការពារសាកល្បង។

នាយកគ្រឹះស្ថានបណ្តុះបណ្តាលត្រូវយោងតាមមតិភាគច្រើនរបស់គណៈកម្មការការពារសាកល្បង ក្នុងការសម្រេចឱ្យបេក្ខជនបន្តទៅការការពារបញ្ចប់ ឬ ផ្អាក។

## ៦.៦ ការវាយតម្លៃនិក្ខេបបទដោយគណៈកម្មការពិនិត្យនិងវាយតម្លៃឯករាជ

ក្រោយពីមានការឯកភាពគ្នារវាងគ្រឹះស្ថានបណ្តុះបណ្តាល និងក្រសួងអប់រំ យុវជន និងកីឡា ទៅលើការជ្រើសរើសគណៈកម្មការពិនិត្យនិងវាយតម្លៃឯករាជ គ្រឹះស្ថានបណ្តុះបណ្តាលត្រូវផ្ញើទៅគ្រប់អ្នកពិនិត្យនិងវាយតម្លៃនូវនិក្ខេបបទមួយច្បាប់ និងព័ត៌មានទាក់ទងនឹងតម្រូវការនានា ដែលអ្នកពិនិត្យនិងវាយតម្លៃត្រូវធ្វើ។

បន្ទាប់ពីបានអាននិងពិនិត្យទៅលើនិក្ខេបបទបេក្ខជនរួច អ្នកពិនិត្យនិងវាយតម្លៃនិក្ខេបបទឯករាជ ត្រូវសរសេររបាយការណ៍បញ្ជូនទៅគ្រឹះស្ថានបណ្តុះបណ្តាល។ របាយការណ៍អ្នកពិនិត្យនិងវាយតម្លៃម្នាក់ៗ គឺជារបាយការណ៍ឯករាជរៀងៗខ្លួន។

ការពិភាក្សាជូនដំណឹងគ្នារវាងអ្នកពិនិត្យនិងវាយតម្លៃឯករាជ និងសាស្ត្រាចារ្យណែនាំ និងបេក្ខបណ្ឌិតត្រូវហាមឃាត់ជាដាច់ខាត មុនពេលលិខិតពិនិត្យនិងវាយតម្លៃរបស់ខ្លួនមិនទាន់បានដាក់ជូននាយកគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិត។

ខ្លឹមសាររបាយការណ៍វាយតម្លៃរបស់អ្នកពិនិត្យនិងវាយតម្លៃឯករាជ រួមមាន៖

- ត្រូវវាយតម្លៃលើ សេចក្តីផ្តើម ប្រវត្តិពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវ គោលបំណងនិងវត្ថុបំណងស្រាវជ្រាវ មូលដ្ឋានទ្រឹស្តីនិងបញ្ញត្តិវិទ្យាសាស្ត្រ វិធីសាស្ត្រស្រាវជ្រាវ លទ្ធផលស្រាវជ្រាវនិងការបកស្រាយពិភាក្សា ការសន្និដ្ឋាន និងអនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ត ទម្រង់នៃការសរសេរឯកសារយោងនិងគន្ធនិទ្ទេស ហើយនិងការរួមចំណែកថ្មីរបស់និក្ខេបបទ។

- ត្រូវបញ្ជាក់ទៅលើខ្លឹមសារដែលបានលើកយកមកបកស្រាយក្នុងជំពូកនីមួយៗ គឺគ្មានការឃ្លាតឆ្ងាយពីប្រធានបទ។ ប្រធានបទនិក្ខេបបទស្រាវជ្រាវ មិនឃ្លាតឆ្ងាយពីស្នាដៃដែលបានចុះផ្សាយនៅក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រជាតិ និងអន្តរជាតិ ដែលបេក្ខជនបានអះអាង។

- ផ្នែកខាងដើមនៃរបាយការណ៍វាយតម្លៃត្រូវលើកឡើងឱ្យបានគ្រប់គ្រាន់នូវព័ត៌មាននៃឈ្មោះប្រធានបទ មុខជំនាញ ឈ្មោះបេក្ខជន ភារកិច្ចនិងតួនាទីរបស់សាស្ត្រាចារ្យវាយតម្លៃ មុខជំនាញនិងអង្គភាពបំរើការ។ នៅផ្នែកចុងក្រោយ នៃរបាយការណ៍របស់ខ្លួន ត្រូវបញ្ជាក់ពីយោបល់សរុបចុងក្រោយទៅលើនិក្ខេបបទ។

របាយការណ៍វាយតម្លៃរបស់គណៈកម្មការពិនិត្យនិងវាយតម្លៃឯករាជ ត្រូវផ្ញើទៅឱ្យនាយកគ្រប់គ្រងកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បណ្ឌិតនៃគ្រឹះស្ថានបណ្ដុះបណ្ដាល ឱ្យបាន៣០ថ្ងៃមុនថ្ងៃដែលគណៈកម្មការវាយតម្លៃនិក្ខេបបទបណ្ឌិតបញ្ចប់ប្រជុំវាយតម្លៃ។ រាល់របាយការណ៍វាយតម្លៃរបស់អ្នកពិនិត្យនិងវាយតម្លៃនិក្ខេបបទឯករាជម្នាក់ៗដែលជាការសម្ងាត់ត្រូវបិទស្រោមឱ្យជិត និងមានចុះហត្ថលេខាចំណាំត្រឹមត្រូវ។

ក្នុងរបាយការណ៍វាយតម្លៃរបស់អ្នកពិនិត្យនិងវាយតម្លៃនិក្ខេបបទឯករាជ មិនត្រូវមានសំណូមពរណាមួយ ឬសេចក្ដីណែនាំណាមួយឡើយ។ ប្រសិនបើមានដូចខាងលើនាយកគ្រប់គ្រងកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បណ្ឌិតត្រូវផ្ញើទៅឱ្យសាស្ត្រាចារ្យនោះវាយតម្លៃឡើងវិញឱ្យបានត្រឹមត្រូវតាមការកំណត់។

## ៦.៧ សំណុំឯកសារសុំការពារបញ្ចប់

សំណុំលិខិតដែលត្រូវផ្ញើទៅក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការសុំការពារនិក្ខេបបទបញ្ចប់មានៈ

- លិខិតស្នើសុំការការពារនិក្ខេបបទរបស់បេក្ខបណ្ឌិត
- លិខិតស្នើសុំឱ្យបេក្ខជនការពារ របស់សាស្ត្រាចារ្យណែនាំគោលដែលមានអំណះអំណាងទៅលើស្នាដៃស្រាវជ្រាវ និងគុណភាពនិក្ខេបបទរបស់បេក្ខជន។
- ស្នាដៃអត្ថបទចុះផ្សាយលើទស្សនាវដ្ដីវិទ្យាសាស្ត្ររបស់បេក្ខជនកម្រិតជាតិចំនួនពីរ(២) ឬកម្រិតអន្តរជាតិចំនួនមួយ(១) (ថតចម្លង)
- លិខិតវាយតម្លៃលើទ្រង់ទ្រាយ និងគុណភាពនិក្ខេបបទរបស់គណៈកម្មការពិនិត្យនិងវាយតម្លៃឯករាជទាំងបី(៣)រូប ដោយបិទស្រោមជិត
- លិខិតស្នើសុំអនុញ្ញាតឱ្យបេក្ខជនការពារបញ្ចប់របស់គ្រឹះស្ថានបណ្ដុះបណ្ដាលដែលមានអំណះអំណាងទៅលើទ្រង់ទ្រាយ ខ្លឹមសារ និងលក្ខណៈវិទ្យាសាស្ត្រនៃនិក្ខេបបទរបស់បេក្ខជន
- ពង្រាងលិខិតឧទ្ទេសនាមសុំបង្កើតគណៈកម្មការវាយតម្លៃនិក្ខេបបទដែលស្នើឡើងដោយគ្រឹះស្ថានបណ្ដុះបណ្ដាល
- ប្រវត្តិរូបសង្ខេបរបស់បេក្ខបណ្ឌិត
- ព្រឹត្តិបត្តិពិន្ទុដែលបានសិក្សាដោយជោគជ័យលើគ្រប់ផ្នែកមុខវិជ្ជាសិក្សាតាមកម្មវិធីកំណត់របស់គ្រឹះស្ថានបណ្ដុះបណ្ដាល
- ច្បាប់ថតចម្លងសញ្ញាបត្របរិញ្ញាបត្រនិងបរិញ្ញាបត្រជាន់ខ្ពស់ (ដោយមានការបញ្ជាក់ពីសាលារាជធានីឬសាលាខេត្ត)

## ៦.៨ លក្ខខណ្ឌសម្រាប់ការឱ្យការពារបញ្ចប់

- និស្សិតត្រូវបញ្ចប់ដោយជោគជ័យគ្រប់មុខវិជ្ជាសិក្សានៅក្នុងកម្មវិធីនិងការប្រឡងទូទៅឬការសរសេរសារណាបទពិសោធន៍វិជ្ជាជីវៈនៅចុងដំណាក់កាលទីមួយ ហើយនិងប្រគល់ជូននិក្ខេបបទរបស់គេសម្រាប់ការវាយតម្លៃ

• និស្សិតត្រូវផ្តល់កាលបរិច្ឆេទនៃការបញ្ចប់ដោយជោគជ័យនិងលទ្ធផលបង្ហាយតម្លៃនីមួយៗសម្រាប់គ្រប់មុខវិជ្ជាសិក្សានិងការប្រឡងទូទៅ ការចូលរួមសិក្ខាសាលានិងការធ្វើសិក្ខាសាលា ឱ្យគ្រប់តាមចំនួនកំណត់ហើយនិងការចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិឬកម្រិតអន្តរជាតិយ៉ាងហោចណាស់ឱ្យបានបួនខែមុនការឡើងការពារនិក្ខេបបទបញ្ចប់។

• និក្ខេបបទត្រូវបានគាំទ្រដោយគណៈកម្មការពិនិត្យនិងវាយតម្លៃឯករាជដោយសំឡេងភាគច្រើន

• ក្រោយពីបានផ្ទៀងផ្ទាត់ការបំពេញលក្ខខណ្ឌខាងដើមបានគ្រប់សព្វហើយ ប្រធានក្រុមប្រឹក្សាវិទ្យាសាស្ត្រ ឬនាយកគ្រប់គ្រងកម្មវិធីថ្នាក់បណ្ឌិតអាចធ្វើការសម្រេចក្នុងការរៀបចំឱ្យបេក្ខបណ្ឌិតឡើងការពារនិក្ខេបបទបញ្ចប់របស់ខ្លួនជាសាធារណៈ។

## ៦.៩ ការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់

នៅពេលចុងក្រោយនៃការការពារនិក្ខេបបទបញ្ចប់គណៈកម្មការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់ត្រូវប្រកាសនូវលទ្ធផលតាមកម្រិតដូចខាងក្រោម ៖

ក. និក្ខេបបទមានតម្លៃស័ក្តិសមជានិក្ខេបបទកម្រិតបណ្ឌិត

ខ. និក្ខេបបទមានតម្លៃស័ក្តិសមជានិក្ខេបបទកម្រិតបណ្ឌិត បន្ទាប់ពីបានកែលម្អបន្តិចបន្តួចតាមការស្នើសុំ

គ. និក្ខេបបទមានតម្លៃជានិក្ខេបបទកម្រិតបណ្ឌិត បន្ទាប់ពីមានការកែលម្អឡើងវិញតាមការណែនាំរបស់គណៈកម្មការវាយតម្លៃ។ ក្នុងករណីនេះ និស្សិតត្រូវពិគ្រោះយោបល់ជាមួយសាស្ត្រាចារ្យណែនាំគោល ដើម្បីកែលម្អនិក្ខេបបទឡើងវិញនិងដាក់ជូនគណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់ពិនិត្យឯកភាព មុនដាក់ជូនគ្រឹះស្ថានបណ្តុះបណ្តាល។

ឃ. និក្ខេបបទមិនទាន់មានតម្លៃជានិក្ខេបបទកម្រិតបណ្ឌិតនៅឡើយ។ ក្នុងករណីនេះ បេក្ខជនអាចនឹងសុំដាក់និក្ខេបបទពិនិត្យនិងវាយតម្លៃឡើងវិញក្នុងរយៈពេលណាមួយដែលកំណត់ដោយគណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់ (យ៉ាងតិចមួយឆ្នាំ) ប៉ុន្តែមិនអនុញ្ញាតឱ្យការពារជាលើកទីបី(៣)។

ង. សញ្ញាបត្របណ្ឌិតមិនត្រូវបានប្រគល់ជូន ហើយការចុះឈ្មោះជានិស្សិតថ្នាក់បណ្ឌិតត្រូវបញ្ឈប់។

## ៦.១០ ការការពារនិក្ខេបបទឡើងវិញ

បើសិនជានិក្ខេបបទមិនត្រូវបានគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់យល់ព្រមនោះទេ បេក្ខជនបណ្ឌិតត្រូវបានអនុញ្ញាតឱ្យធ្វើការកែសម្រួលនិក្ខេបបទឡើងវិញ ហើយដាក់ស្នើសុំការពារជាលើកទីពីរដោយយឺតបំផុតត្រឹម២៤ខែ គិតចាប់ពីថ្ងៃដែលបានការពារលើកទីមួយ។

សមាសភាពគណៈកម្មការវាយតម្លៃនិក្ខេបបទត្រូវដូចគ្នាទៅនឹងសមាសភាពគណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់លើកទីមួយដែរ។ បើសិនជាសមាជិកគណៈកម្មការណាម្នាក់អវត្តមាន គ្រឹះស្ថានបណ្តុះបណ្តាលត្រូវស្នើសុំទៅក្រសួងអប់រំ យុវជន និងកីឡាដើម្បីបំពេញជំនួស។

មិនអនុញ្ញាតឱ្យការពារនិក្ខេបបទជាលើកទីបី។

ហួសរយៈពេល២៤ខែគិតចាប់ពីថ្ងៃការពារលើកទីមួយ និក្ខេបបទក៏មិនអនុញ្ញាតឱ្យការពារដែរ។

សំណុំបែបបទនិងលំដាប់លំដោយសម្រាប់រៀបចំឱ្យបេក្ខបណ្ឌិតការពារនិក្ខេបបទឡើងវិញ ត្រូវផ្អែកទៅតាមសេចក្តីបញ្ជាក់លម្អិតរបស់គណៈកម្មការគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតគ្រឹះស្ថានបណ្តុះបណ្តាល និង ក្រសួងអប់រំ យុវជន និងកីឡា។

# ជំពូកទី៧
# ការពិនិត្យយល់ព្រមលើនិក្ខេបបទនិងការប្រគល់សញ្ញាបត្រ

## ៧.១ ការពិនិត្យនិងយល់ព្រមលើនិក្ខេបបទ

យ៉ាងយូរមួយខែក្រោយពេលគណៈកម្មការការពារនិក្ខេបបទបញ្ចប់សម្រេចឱ្យបេក្ខជនជាប់ជាស្ថាពររួច នាយកគ្រឹះស្ថានបណ្តុះបណ្តាលត្រូវរៀបចំរបាយការណ៍ស្តីពីការការពារនិក្ខេបបទបញ្ចប់របស់បេក្ខបណ្ឌិតដើម្បីបញ្ជូនមកក្រសួង អប់រំ យុវជន និងកីឡា។ សំណុំឯកសាររបាយការណ៍ទាំងនោះ រួមមាន ៖

ក. លិខិតផ្លូវការរបស់គ្រឹះស្ថានបណ្តុះបណ្តាលដែលក្នុងនោះមានបញ្ជាក់ពីឈ្មោះ(ឬបញ្ជីឈ្មោះ) បេក្ខបណ្ឌិត និងកាលបរិច្ឆេទឡើងការពារបញ្ចប់

ខ. ច្បាប់ចម្លងលិខិតឧទ្ទេសនាមបង្កើតគណៈកម្មការវាយតម្លៃនិក្ខេបបទពេលឡើងការពារបញ្ចប់ និងគណៈកម្មការពិនិត្យនិងវាយតម្លៃឯករាជនិក្ខេបបទមុនពេលឱ្យឡើងការពារ ចេញដោយក្រសួងអប់រំ យុវជន និងកីឡា ឬថ្នាក់ប្រហាក់ប្រហែល

គ. របាយការណ៍និងសេចក្តីសម្រេចរបស់គណៈកម្មការពិនិត្យនិងវាយតម្លៃឯករាជនិក្ខេបបទ និងកំណត់ហេតុរបស់គណៈកម្មការវាយតម្លៃនិក្ខេបបទនៅពេលការការពារបញ្ចប់ និង

ឃ. ទំព័រផ្តល់ព័ត៌មានស្តីពីការរួមចំណែកថ្មីអំពីផ្នែកទ្រឹស្តី វិធីសាស្ត្រ និងអភិវឌ្ឍន៍ដែលធ្វើឡើងដោយគណៈកម្មការការពារបញ្ចប់។

បើបេក្ខបណ្ឌិតពុំបានត្រូវគេចោទប្រកាន់/តវ៉ា ឬលិខិតជំទាស់ណាមួយទេ និង លទ្ធផលវាយតម្លៃការការពារនិក្ខេបបទរបស់គណៈកម្មការការពារបញ្ចប់ថាសាកសមជានិក្ខេបបទកម្រិតបណ្ឌិតដោយមិនចាំបាច់កែលម្អហើយនិងមានសំណុំឯកសារទាំងបួនខាងលើគ្រប់គ្រាន់ ក្រសួងអប់រំ យុវជន និងកីឡាពិនិត្យនិងប្រគល់សញ្ញាបត្របណ្ឌិតជូនបេក្ខជននោះយ៉ាងតិចរយៈពេលបី(៣)ខែក្រោយថ្ងៃប្រគល់សំណុំលិខិតគ្រប់គ្រាន់។

ចំពោះនិក្ខេបបទដែលត្រូវបានវាយតម្លៃដោយគណៈកម្មការការពារថាចាំបាច់ត្រូវមានការបំពេញបន្ថែមឬកែលម្អបន្តិចបន្តួច ត្រូវមានរបាយការណ៍អំពីការកែលម្អឬការបំពេញបន្ថែមនេះដែលធ្វើឡើងដោយបេក្ខបណ្ឌិតនិងសាស្ត្រាចារ្យណែនាំគោលភ្ជាប់មកជាមួយបន្ថែមទៀត។

ចំពោះនិក្ខេបបទដែលត្រូវបានវាយតម្លៃថាចាំបាច់ត្រូវមានការកែលម្អឡើងវិញតាមគណៈកម្មការការពារបញ្ចប់ក្រោយពេលបេក្ខបណ្ឌិតធ្វើការបំពេញបន្ថែមនិងកែលម្អដោយមានការផ្ទៀងផ្ទាត់ពីសាស្ត្រាចារ្យណែនាំគោលរួច ប្រធានគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់ត្រូវត្រួតពិនិត្យនិងយល់ព្រមលម្អិតអំពីខ្លឹមសារដែលបានកែលម្អនិងបំពេញបន្ថែមទាំងនោះ។ ករណីនេះត្រូវមានរបាយការណ៍អំពីខ្លឹមសារដែលខ្លួនបានបំពេញបន្ថែមនិងកន្លែងដែលបានកែលម្អរបស់បេក្ខជនដោយមាន បញ្ជាក់ការបានផ្ទៀងផ្ទាត់ពីសាស្ត្រាចារ្យណែនាំគោល និងការបានត្រួតពិនិត្យនិងយល់ព្រមដោយប្រធានគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់ ដែលជាឯកសារបន្ថែមទៅលើឯកសារទាំងបួនខាងលើ។

## ៧.២ សំណុំឯកសារសម្រាប់ការផ្តល់សញ្ញាបត្រ

ការផ្តល់សញ្ញាបត្រ ត្រូវមានលក្ខខណ្ឌដូចខាងក្រោម ៖

- ក្រោយពីបានការពារបញ្ចប់សព្វគ្រប់យ៉ាងយឺតចំនួនមួយ(១)ខែ គ្រឹះស្ថានបណ្តុះបណ្តាលត្រូវរៀបចំសំណុំបែបបទឱ្យបានគ្រប់គ្រាន់ ដើម្បីបញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡាពិនិត្យនិងសម្រេចផ្តល់សញ្ញាបត្រ។
- សំណុំបែបបទដែលត្រូវផ្ញើទៅក្រសួងអប់រំ យុវជន និងកីឡាមាន៖

    ១. កំណត់ហេតុលម្អិតពេលការពារនិក្ខេបបទបញ្ចប់

២. សេចក្តីសម្រេចរបស់គណៈកម្មការវាយតម្លៃនិក្ខេបបទ

៣. លិខិតវាយតម្លៃរបស់គណៈកម្មការគ្រប់រូប

៤. លិខិតឧទ្ទេសនាមបង្កើតគណៈកម្មការពិនិត្យនិងវាយតម្លៃឯករាជ

៥. លិខិតឧទ្ទេសនាមបង្កើតគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់

៦. លិខិតកែលម្អនិក្ខេបបទរបស់បេក្ខជនដូចមានចែងក្នុងប្រការ៦៦

៧. ប្រវត្តិរូបនិងរូបថតទើបថតថ្មី 4x6 ចំនួន៤សន្លឹក របស់បេក្ខជន។

- ក្រោយពេលសំណុំបែបបទត្រូវរៀបចំគ្រប់គ្រាន់ យ៉ាងយូរយៈពេលបី(៣) ខែដោយគិតចាប់ពីថ្ងៃដែលគ្រឹះស្ថានបណ្តុះបណ្តាលប្រគល់សំណុំបែបបទជូនក្រសួង បើគ្មានលិខិតជំទាស់ ក្រសួងអប់រំ យុវជន និងកីឡាសម្រេចទទួលស្គាល់ថាបេក្ខជនជាបណ្ឌិតពេញលក្ខណៈ និងប្រគល់សញ្ញាបត្រជូន។

**៧.៣ ការផ្តល់សញ្ញាបត្រ**

ក្រោយពីមានការស្នើសុំពិនិត្យនិងយល់ព្រមជាផ្លូវការប្រគល់សញ្ញាបត្របណ្ឌិតដោយគ្រឹះស្ថានបណ្តុះបណ្តាលដែលមានភ្ជាប់នូវ សំណុំឯកសារគ្រប់គ្រាន់ ក្រសួងអប់រំ យុវជន និងកីឡាមានភារកិច្ចរៀបចំការត្រួតពិនិត្យអំពីដំណើរការបណ្តុះបណ្តាល គុណភាពរបស់និក្ខេបបទ ការងារចាត់តាំង និងសកម្មភាពរបស់គណៈកម្មការវាយតម្លៃពាក់ព័ន្ធនានារបស់និក្ខេបបទបេក្ខបណ្ឌិតដែលស្នើសុំសញ្ញាបត្រ មុននឹងសម្រេចប្រគល់សញ្ញាបត្របណ្ឌិតទៅឱ្យបេក្ខជននីមួយៗ។

## ជំពូកទី៨
## យន្តការត្រួតពិនិត្យគុណភាព

**៨.១ លក្ខខណ្ឌបឋម**

គ្រឹះស្ថានបណ្តុះបណ្តាលត្រូវប្រឹងប្រែងឱ្យបានឧត្តមភាពនៃគុណភាពលើគ្រប់ទិដ្ឋភាពទាំងអស់នៃការបណ្តុះបណ្តាលថ្នាក់បណ្ឌិតរបស់ខ្លួន។ ដើម្បីជំរុញឱ្យបាននូវឧត្តមភាពនៃគុណភាពនៅក្នុងសកម្មភាពស្រាវជ្រាវនិងការបង្រៀន គ្រឹះស្ថានបណ្តុះបណ្តាលត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម ៖

• ការគ្រប់គ្រងការងារស្រាវជ្រាវនិងសកម្មភាពស្រាវជ្រាវ គឺជាការងារសំខាន់បំផុតរបស់គ្រឹះស្ថានបណ្តុះបណ្តាលកម្មវិធីថ្នាក់បណ្ឌិត ដែលគាំទ្រដោយរចនាសម្ព័ន្ធសិក្សាសមស្របមានចរិតវិទ្យាសាស្ត្រ។

• រាល់សំណើស្រាវជ្រាវសម្រាប់ការស្រាវជ្រាវថ្នាក់បណ្ឌិត ត្រូវមានការយល់ព្រមនិងឯកភាពពីក្រុមប្រឹក្សាវិទ្យាសាស្ត្ររបស់គ្រឹះស្ថានបណ្តុះបណ្តាល។

• រាល់គម្រោងស្រាវជ្រាវទាំងអស់ត្រូវតែទទួលបានការគាំទ្រផ្នែកសិក្សានិងបច្ចេកទេសពីគ្រឹះស្ថានបណ្តុះបណ្តាល លើកលែងតែគម្រោងស្រាវជ្រាវណាដែលគ្រឹះស្ថាននោះពុំមានធនធានគ្រប់គ្រាន់។

• គ្រប់មុខវិជ្ជាសិក្សាក្នុងកម្មវិធីថ្នាក់បណ្ឌិតទាំងអស់ត្រូវបង្រៀនដោយសាស្ត្រាចារ្យដែលជាអ្នកសកម្មក្នុងការងារស្រាវជ្រាវលើវិស័យនោះ។

ក្រុមប្រឹក្សាវិទ្យាសាស្ត្ររបស់គ្រឹះស្ថានបណ្តុះបណ្តាល ត្រូវយល់ព្រមនិងឯកភាពចំពោះការសុំចូលសិក្សាថ្នាក់បណ្ឌិតដោយពិនិត្យយ៉ាងយកចិត្តទុកដាក់ទៅលើ ៖

- កម្រិតគុណភាពរបស់គម្រោងស្រាវជ្រាវ
- គុណវុឌ្ឍិរបស់អ្នកដាក់ពាក្យសុំចូលសិក្សា
- ភាពត្រឹមត្រូវនិងសមស្របនៃការចាត់ចែងគណៈកម្មការសាស្ត្រាចារ្យណែនាំ
- លទ្ធភាពគ្រប់គ្រាន់អំពីធនធាន

- ទីកន្លែងសម្រាប់សិក្សាសមស្របនិងសមរម្យ
- ការខិតខំចំណាយពេលវេលាសិក្សារបស់និស្សិត(ចំពោះនិស្សិតសិក្សាមិនពេញម៉ោង)។

គ្រឹះស្ថានបណ្តុះបណ្តាលត្រូវរក្សាកំណត់ត្រារាល់ឯកសារនិងលទ្ធផលសិក្សារបស់និស្សិតម្នាក់ៗដែលបានចុះឈ្មោះចូលសិក្សាកម្មវិធីថ្នាក់បណ្ឌិតសម្រាប់ដាក់ជូនក្រុមប្រឹក្សាវិទ្យាសាស្ត្រពិនិត្យតាមតម្រូវការ។

**៨.២ គុណភាពនិក្ខេបបទ**

និក្ខេបបទថ្នាក់បណ្ឌិតត្រូវតែអនុវត្តដោយបេក្ខបណ្ឌិតផ្ទាល់ និងបំពេញតាមតម្រូវការនៃគោលបំណង និងលក្ខខណ្ឌដែលបានកំណត់ ដូចមានចែងក្នុងប្រការ៣៣នៃប្រកាសនេះ។

ក្រសួងអប់រំ យុវជន និងកីឡា ប្រគល់ភារកិច្ចទៅឱ្យគ្រឹះស្ថានបណ្តុះបណ្តាល (មហាវិទ្យាល័យ/ វិទ្យាស្ថាន ឬក្រុមមុខជំនាញ) ជាអ្នកកំណត់នូវគំរូមួយអំពីការសរសេរនិក្ខេបបទ ទៅតាមជំនាញឯកទេសនីមួយៗ ដោយធានាឱ្យបានថានិក្ខេបបទដែលមានលក្ខណៈវិទ្យាសាស្ត្រច្បាស់លាស់ និងមានលំដាប់លំដោយតាមស្តង់ដាជាតិនិងអន្តរជាតិពិតប្រាកដ។

## ជំពូកទី៩
## យន្តការដោះស្រាយទំនាស់

ពេលខ្លះទំនាស់រវាងនិស្សិតនិងគ្រឹះស្ថានបណ្តុះបណ្តាលអាចកើតមាន។ ដំណោះស្រាយទំនាស់បែបនេះគប្បីត្រូវធ្វើឡើងដោយលក្ខណៈមិត្តភាពក្នុងករណីដែលអាចសម្របសម្រួលបាន។ បើទំនាស់ពុំអាចដោះស្រាយដោយងាយស្រួលបានទេ លំនាំផ្លូវការណាមួយត្រូវតែរៀបចំឡើងចំពោះករណីជាក់ស្តែង។

បណ្តឹង ឬការតវ៉ាណាមួយគប្បីត្រូវបានដោះស្រាយជាមួយសាស្ត្រាចារ្យណែនាំគោលភ្លាមៗជាមុនសិន។ ប្រសិនបើការដោះស្រាយបញ្ហានោះមិនទាន់មានលក្ខណៈសមស្របដែលអាចឱ្យនិស្សិតទទួលយកបាន ក្រុមប្រឹក្សាវិទ្យាសាស្ត្ររបស់គ្រឹះស្ថានបណ្តុះបណ្តាលគប្បីផ្តល់ការប្រឹក្សានិងធ្វើការសម្រេចចិត្តណាមួយហើយបញ្ជូនទៅសាមីនិស្សិតតាមរយៈសាស្ត្រាចារ្យណែនាំគោល។

បើនិស្សិតនៅតែមិនព្រមទទួលយកនូវការសម្រេចចិត្តនោះ ការតវ៉ាគប្បីធ្វើឡើងជាលាយលក្ខណ៍អក្សរទៅគ្រឹះស្ថានបណ្តុះបណ្តាលតាមរយៈការិយាល័យឬផ្នែកទទួលបន្ទុកបណ្តុះបណ្តាលកម្មវិធីថ្នាក់បណ្ឌិត ដែលប្រែក្លាយទៅជាការប្តឹងតវ៉ាផ្លូវការ។ និស្សិតនោះនឹងទទួលនូវបង្កាន់ដៃដែលបញ្ជាក់ថាពាក្យបណ្តឹងនោះត្រូវបានទទួលហើយ និង ត្រូវដោះស្រាយវា។ ចម្លើយជាលាយលក្ខណ៍អក្សរមួយនឹងធ្វើឡើងសម្រាប់ការដោះស្រាយបញ្ហាផ្សេងៗ នៃបណ្តឹងដែលនឹងត្រូវបានចងក្រងឡើង។

រាល់បញ្ហាទាំងឡាយណាដែលគ្រឹះស្ថានបណ្តុះបណ្តាលពុំអាចដោះស្រាយបាននៅក្នុងរង្វង់កម្រិតសមត្ថភាពរបស់ខ្លួនបានទេ ត្រូវបញ្ជូនទៅឱ្យក្រសួងអប់រំ យុវជន និងកីឡាជាអ្នកដោះស្រាយចុងក្រោយ។

## ជំពូកទី១០
## ភារកិច្ចបន្តរបស់គ្រឹះស្ថានបណ្តុះបណ្តាល

គ្រឹះស្ថានបណ្តុះបណ្តាលនីមួយៗ ត្រូវរៀបចំអភិវឌ្ឍព័ត៌មានលម្អិតអំពីធនធាន លិខិតបទដ្ឋាន និងបទបញ្ញត្តិនានា ទាក់ទងនឹងលក្ខខណ្ឌឱ្យចូលរៀន កម្មវិធីសិក្សា ដំណើរការសិក្សា រចនាសម្ព័ន្ធគ្រប់គ្រងនិងត្រួតពិនិត្យ វាយតម្លៃហើយនិងសកម្មភាពនានាសម្រាប់គាំទ្រការបណ្តុះបណ្តាលថ្នាក់បណ្ឌិតរបស់ខ្លួន។ រាល់លិខិតបទដ្ឋានទាំងឡាយនោះត្រូវផ្អែកតាមស្មារតីអនុក្រឹត្យលេខ ១៥១ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ និងប្រកាសក្រសួងអប់រំ យុវជន និងកីឡា ធ្វើជាមូលដ្ឋាន។